ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៥ លេខ១ | មករា - មីនា ឆ្នាំ២០១១ | តម្លៃ ១.៥០០រ

# ព្រៃឈើ និងការរួមចំណែករបស់ព្រៃឈើ ដល់ជីវភាពនៅមូលដ្ឋាន[១]


ផលិតផលព្រៃឈើ ជាសំណាញ់សុវត្ថិភាពដ៏សំខាន់ សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ នៅឃុំសង្កែសាទប ខេត្តកំពង់ស្ពឺ ឆ្នាំ២០១០ ។

## សេចក្ដីផ្ដើម

ព្រៃឈើ ដើរតួនាទីសំខាន់ក្នុងប្រព័ន្ធសុវត្ថិភាពគាំពារជីវភាព ជាពិសេសក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ ដែលធ្វើឲ្យប្រជាជនខូចខាត ឬបាត់បង់នូវផលិតផលកសិកម្ម ដោយសារគ្រោះមហន្តរាយផ្សេងៗ ដូចជា ទឹកជំនន់ ការរាំងស្ងួត កត្តាសត្វល្អិតចង្រៃបំផ្លាញ ឬជំងឺឆ្លងនៃសត្វពាហនៈ ជាដើម ។ ក្នុងស្ថានភាពនេះ ប្រជាជន ត្រូវពឹងផ្អែកលើធនធានព្រៃឈើ សម្រាប់ប្រើជាអាហារ ចំណីសត្វ ឱសថ និងផលិតផលជាច្រើនទៀត ។ អង្គការសហគមន៍ព្រៃឈើអន្តរជាតិ (CFI) (2006) លើកឡើងថា ផលនិងអនុផលព្រៃឈើ (NTFPs) មិនត្រឹមតែបម្រើការជាប្រព័ន្ធសុវត្ថិភាព ក្នុងពេលមានកង្វះស្បៀងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាប្រភពដ៏មានតម្លៃនៃចំណូលគ្រួសារ និងសម្ភារៈផ្សេងៗទៀតផង ។ នៅតំបន់ជនបទ ព្រៃឈើជាប្រភពធនធាន និងផលិតផលដ៏សំខាន់សម្រាប់ជួយលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើម ធ្វើឲ្យពួកគេមានភាពបន្សាំល្អនឹងបម្រែបម្រួលផ្សេងៗ (FAO 2010) ។

ព្រៃឈើផ្ដល់ផលប្រយោជន៍ជាច្រើន តាំងពីការស្រូបទុកសារធាតុកាបូន បម្រើផលប្រយោជន៍សាធារណជនក្នុងសាកលលោក រហូតដល់ការរួមចំណែកយ៉ាងសំខាន់លើកកំពស់ជីវភាពប្រជាជនអ្នកប្រើប្រាស់ព្រៃឈើ ។ មានការទទួលស្គាល់ជាទូទៅថា ធនធានព្រៃឈើចូលរួមចំណែកច្រើនបែបយ៉ាងក្នុងជីវភាពរស់នៅរបស់ប្រជាជន ។ ផលិតផល និងសេវាកម្មព្រៃឈើសំខាន់ខ្លាំងណាស់ក្នុងការផ្ដល់ជាអាហារ ឱសថ ចំណីសត្វ ជំរក ឥន្ធនៈ ឈើប្រើការ និងសម្ភារៈសំណង់ ។ ការងារជាប់ទាក់ទងជាមួយព្រៃឈើ ដូចជា ការលក់អុសធ្យូង ផ្នែកសិប្បកម្ម និងផលិតផលផ្សេងទៀត បានពីផល និងអនុផលព្រៃឈើ សុទ្ធតែផ្ដល់ចំណូលជាសាច់ប្រាក់ ។ ម្យ៉ាងទៀត វិស័យព្រៃឈើផ្ដល់នូវការងារជាក់លាក់ និងការងារបន្ទាប់បន្សំជាច្រើន ព្រមទាំងជាប្រភពចំណូលរូបិយវត្ថុបរទេសដ៏សំខាន់ទៀតផង ។ ក្នុងការវិភាគពីចង្វាក់ពាណិជ្ជកម្មផលិតផលជ័រទឹកនៅកម្ពុជា លោក តុលា (២០០៩) រាយការណ៍ថា តម្លៃនៅទីផ្សារក្នុងស្រុក និងតម្លៃ

## មាតិកា

ព្រៃឈើ និងការរួមចំណែករបស់ព្រៃឈើដល់ជីវភាពនៅមូលដ្ឋាន ........ ១
គណនេយ្យភាពនៅកម្ពុជា៖ ទ្រឹស្ដី និងការអនុវត្ត ........ ៧
ការប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (PSM) ដើម្បីបង្កើតគំរូតាងប្រៀបធៀបក្នុងការវាយតម្លៃគម្រោង៖ ករណីសិក្សានៃគម្រោងដឹកជញ្ជូន ........ ១៤
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៨
— ស្ថានភាពក្នុងប្រទេស ........ ២០
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........ ២៨

[១] អត្ថបទនេះរៀបរៀងដោយលោក កុយ រ៉ា ជាអ្នកសម្របសម្រួលកម្មវិធី និងលោក លន់ ពេជ្រតារា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ដោយដកស្រង់ចេញពីឯកសារ "តម្លៃនៃព្រៃឈើសម្រាប់ជីវភាពនៅមូលដ្ឋាន" (ចេញផ្សាយក្នុងពេលឆាប់ៗ) និងឯកសារពិភាក្សារបស់បណ្ដាញខាងបរិស្ថាន និងភាពក្រីក្រ (PEN) (ចេញផ្សាយក្នុងពេលឆាប់ៗ) ។

នាំចេញប្រចាំឆ្នាំ នៃជ័រទឹកប្រមូលបានក្នុងមួយឆ្នាំៗ ប្រមាណ ១១.០០០តោន ទៅ ១៨.០០០តោន មានប្រហែល ៤,៧លានដុល្លារ ទៅ ៧,៦លានដុល្លារ ។

ប្រជាជនជនបទភាគច្រើន ពឹងផ្អែកលើធនធានព្រៃឈើ ដើម្បីដោះស្រាយតម្រូវការប្រើប្រាស់ថាមពល ។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣ (RGC ២០១០) នៅឆ្នាំ២០០៨ គ្រួសារនៅកម្ពុជាសរុប ៧៣% ពឹងផ្អែកលើអុស ហើយអត្រានេះធ្លាក់ចុះមកត្រឹម ៦៧% នៅឆ្នាំ២០០៩ និង ៦១% នៅឆ្នាំ២០១០ ។ ក្រៅពីការប្រើប្រាស់ឈើជាប្រភពថាមពល ប្រជាជនជនបទត្រូវការឈើ សម្រាប់ប្រើជាសម្ភារៈសំណង់ និងប្រមូលផលនិងអនុផលព្រៃឈើជាច្រើនទៀត ដូចជាឫស្សី ទំពាំង និងបន្លែព្រៃ ដើម្បីលើកកម្ពស់ជីវភាព និងបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃរបស់ខ្លួន ។ ព្រៃឈើដើរតួនាទីដ៏សំខាន់ ក្នុងការធានាសុវត្ថិភាពស្បៀងអាហារសម្រាប់ប្រជាជនមូលដ្ឋាន ជាពិសេសសម្រាប់សហគមន៍ស្ថិតនៅក្បែរព្រៃឈើ ។ ក្នុងឆ្នាំ២០០៨ អនុវិស័យព្រៃឈើរួមចំណែក ៦,៩% នៃ ផសសសរុបរបស់វិស័យកសិកម្ម (Chao 2009) ។

ពិតហើយ ព្រៃឈើផ្ដល់ផលប្រយោជន៍ជាច្រើនដល់ប្រជាជនមូលដ្ឋាន ប៉ុន្តែដោយសារយើងមិនដឹងពីតម្លៃគិតជាប្រាក់នៃធនធាន ដែលប្រជាជនមូលដ្ឋានទាញយកពីព្រៃឈើ ដូច្នេះយើងក៏មិនដឹងថា តើព្រៃឈើរួមចំណែកប៉ុណ្ណាដល់ការកាត់បន្ថយភាពក្រីក្រដែរ ។ មានការសិក្សាជាច្រើនបានធ្វើឡើងនៅកម្ពុជា ប៉ុន្តែ របាយការណ៍ទាក់ទងនឹងតម្លៃពិតប្រាកដនៃធនធានព្រៃឈើសម្រាប់ជីវភាពមូលដ្ឋាន មានតិចតួចណាស់ ។ លទ្ធផលការសិក្សាភាគច្រើន ទទួលបានពីសម្ភាសន៍សុំព័ត៌មានលើអំឡុងពេលមួយយ៉ាងខ្លី ឬការពិភាក្សាតាមក្រុមស្នូលផ្អែកលើព័ត៌មានអ្នកចូលរួមបានចងចាំក្នុងរយៈពេលមួយឆ្នាំពេញ ដែលអាចមានការភ្លេចភ្លាំង ការរាយការណ៍មិនអស់ ឬការរាយការណ៍ពីរដងអំពីផលព្រៃឈើប្រមូលបាន ។ អ្នកស្រាវជ្រាវដទៃទៀត បានផ្ដោតលើតម្លៃនៃធនធានធម្មជាតិជារួម ចំពោះសហគមន៍មូលដ្ឋាន ប៉ុន្តែមានអ្នកស្រាវជ្រាវតិចនាក់ណាស់ ដែលបានស្វែងរកតម្លៃនៃធនធានព្រៃឈើជាក់លាក់ ចំពោះចំណូលនៅកម្រិតគ្រួសារ ។ ដូច្នេះត្រូវមានការអនុម័តយកវិធីសាស្ត្រមួយ សម្រាប់ប៉ាន់ស្មានតម្លៃផលិតផលព្រៃឈើ ដែលអ្នកប្រើប្រាស់ព្រៃឈើប្រមូលបាន ដើម្បីកែលំអគុណភាពទិន្នន័យ និងទទួលបានលទ្ធផលកាន់តែមានប្រយោជន៍ ។

ឯកសារនេះ ជាលទ្ធផលនៃការសិក្សាមួយស្ដីពី "ព្រៃតំបន់ត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ៖ ការវិភាគតាំងពីទិន្នន័យគ្រួសារដល់ទិន្នន័យសាកល" ដែលជាគម្រោងរួមគ្នារវាង ១) មជ្ឈមណ្ឌលសម្រាប់ព្រៃឈើ ទេសភាព និងការរៀបចំផែនការ (S & L) នៃមហាវិទ្យាល័យវិទ្យាសាស្ត្រជីវិត ប្រចាំសាកលវិទ្យាល័យ Copenhagen (KU) ២) កម្មវិធីព្រៃឈើ និងជីវភាព នៃមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវពីព្រៃឈើអន្តរជាតិ (CIFOR) ៣) វិទ្យាស្ថានស្រាវជ្រាវព្រៃឈើនៃប្រទេសហ្កាណា (FORIG) ៤) ដេប៉ាតេម៉ង់សង្គមវិទ្យានៃសាកលវិទ្យាល័យ Ouagadougou (DSUO) នៃប្រទេស Burkina Faso និង ៥)

ក្រាហ្វិក១៖ តំបន់សិក្សា



វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។ គម្រោងនេះ ទទួលមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្ដរជាតិដាណឺម៉ាក (DANIDA) ។

ការសិក្សានេះផ្ដោតលើ ១) វិធីសាស្ដ្រប៉ាន់ស្មានថ្លៃផលិតផលព្រៃឈើ ដែលរួមមាន ការប្រើប្រាស់ និងការលក់ដូរ និង ២) ការរួមចំណែកនៃចំណូលពីព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនមូលដ្ឋាន ។

## វិធីសាស្ដ្រ

### តំបន់សិក្សា

ការសិក្សាបានអនុវត្តក្នុង ១៥ភូមិ នៅឃុំតាកែន ខេត្តកំពត ឃុំសង្កែសាទប ខេត្តកំពង់ស្ពឺ និងឃុំទំរីង ខេត្តកំពង់ធំ (ក្រាហ្វិក ១) ។ គម្របដីសំខាន់ៗក្នុងឃុំនីមួយៗ មានពិពណ៌នាដោយសង្ខេបនៅខាងក្រោម ។

- *ឃុំតាកែន៖* គម្របដីចំបងៗ រួមមាន ព្រៃស្រោង ព្រៃរបោះ និងព្រៃឈើដុះឡើងវិញ បន្ទាប់ពីរងការបំផ្លិចបំផ្លាញ ។ តំបន់នេះ បើកទូលាយឲ្យអ្នកភូមិទាំងអស់ មានលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ និងមានមួយភាគបានកំណត់ទុកជាតំបន់ការពារធម្មជាតិ ។

- *ឃុំសង្កែសាទប៖* គម្របដីអាចបែងចែកជា ព្រៃរបោះ ព្រៃដុះឡើងវិញ និងព្រៃគុម្ពោត ។ ឃុំបានបង្កើតជាសហគមន៍ព្រៃឈើ ហើយតំបន់នេះជាផ្នែកមួយនៃតំបន់ការពារធម្មជាតិ ។

- *ឃុំទំរីង៖* គម្របដីភាគច្រើនជា ព្រៃស្រោង ព្រៃរបោះ និងព្រៃឈើដុះឡើងវិញ ។ ក្នុងពីរបីឆ្នាំមុនពេលក្រុមស្រាវជ្រាវចុះធ្វើអង្កេត ការប្រើប្រាស់ដីនៅតំបន់នេះ បានប្រែប្រួលយ៉ាងខ្លាំង ដោយសារការបង្កើតចំការកៅស៊ូ ។

### អង្កេតគ្រួសារ

ដើម្បីទទួលបានគំរូតាងល្អ និងលទ្ធផលមានលក្ខណៈតំណាង និងគួរឲ្យជឿជាក់ ក្រុមស្រាវជ្រាវបានធ្វើសម្ភាស ៦០០គ្រួសារ ឬប្រហែល ២០០គ្រួសារ នៅ ៥ភូមិ ក្នុងឃុំនីមួយៗ ។ សម្ភាសន៍នេះធ្វើឡើងជា ៤ដង នៅខែ មករា មីនា-មេសា មិថុនា-កក្កដា និងតុលា-វិច្ឆិកា ក្នុងឆ្នាំ២០០៨ ដើម្បីបង្កើតមូលដ្ឋានសុីគ្នាមួយសម្រាប់ការប្រមូលទិន្នន័យ និងកាត់បន្ថយការលំបាករបស់អ្នកឆ្លើយសម្ភាសន៍ ក្នុងការនឹករកព័ត៌មានទាក់ទងនឹងផលព្រៃឈើដែលខ្លួនបានប្រមូល ។

សម្រាប់ការធ្វើសម្ភាសន៍ ប្រហែល ៤០គ្រួសារ ឬ ១០-៣០% នៃគ្រួសារសរុបក្នុងភូមិនីមួយៗ ត្រូវបានជ្រើសរើសដោយចៃដន្យ និងស្របតាមគោលការណ៍ណែនាំខាងបច្ចេកទេសរបស់បណ្ដាញបរិស្ថាន និងភាពក្រីក្រ (PEN) (២០០៧) ដែលចែងថា គ្រួសារគំរូតាងត្រូវជ្រើសរើសដោយចៃដន្យចេញពីចំនួនប្រជាជនសរុប ។ បន្ទាប់មក មានការបិទសញ្ញាសំគាល់ពណ៌លឿងនៅលើជញ្ជាំងមុខផ្ទះនីមួយៗ ដើម្បីជួយឲ្យអ្នកចុះធ្វើអង្កេតងាយស្រួលស្វែងរកគ្រួសារគំរូតាងទាំងនោះ នៅវគ្គចុះអង្កេតលើកក្រោយៗទៀត ។

គំរូបញ្ជីសំណួរលើកទី៤ របស់ PEN ដែលបានចងក្រងជាភាសាអង់គ្លេស បានយកមកប្រើសម្រាប់ធ្វើអង្កេតគ្រួសារនៅត្រីមាសទី១ ទី២ ទី៣ និងទី៤ ។ បញ្ជីសំណួរបានបកប្រែជាភាសាខ្មែរ ដើម្បីធានាការប្រមូលទិន្នន័យប្រកបដោយគុណភាពខ្ពស់ ។

ដោយសារអង្កេតនេះ ផ្អែកលើការចងចាំរបស់អ្នកឆ្លើយសម្ភាសន៍ អំពីចំណូលដែលពួកគាត់រកបានពីព្រៃឈើ និងផលព្រៃឈើផ្សេងៗ សម្រាប់ការប្រើប្រាស់ក្នុងត្រីមាសនីមួយៗ ដូច្នេះ ទិន្នន័យទទួលបាន អាចមានភាពមិនច្បាស់ ដោយសារអ្នកឆ្លើយសម្ភាសន៍ផ្ដល់ព័ត៌មាន មិនមែនកើតឡើងក្នុងត្រីមាសកំពុងធ្វើអង្កេត ហើយនិងការរាយការណ៍រឿងមួយដល់ទៅពីរដង ។ ដើម្បីធានាថា ទិន្នន័យដែលទទួលបានជាព័ត៌មានក្នុងត្រីមាសកំពុងធ្វើអង្កេត ក្រុមស្រាវជ្រាវបានធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យដែលទទួលបាននៅវគ្គថ្មី ដោយធៀបនឹងទិន្នន័យប្រមូលបាននៅវគ្គមុន ។

### ការប៉ាន់ស្មានថ្លៃផលិតផល

ការសិក្សានេះ សំដៅកំណត់តម្លៃផលិតផលទាំងអស់ ដែលប្រមូលបានពីព្រៃឈើ គិតជាទឹកប្រាក់ ។ ដូច្នេះ ការប្រមូលព័ត៌មានទាក់ទងនឹងថ្លៃផលិតផលព្រៃឈើ ពីក្រុមគ្រួសារគំរូតាងមានសារៈសំខាន់ណាស់ ។ ក្រុមស្រាវជ្រាវបានរៀបចំវិធីសាស្ដ្រចំនួន ៣ ដើម្បីគណនាថ្លៃផលិតផល៖ ថ្លៃទីផ្សារមូលដ្ឋាន របស់ជំនួស និងតម្លៃពេលវេលា ។ វិធីសាស្ដ្រថ្លៃទីផ្សារមូលដ្ឋាន ផ្អែកលើថ្លៃនៅកសិដ្ឋាន ពោលគឺ ថ្លៃលក់ផលិតផល ។ វិធីសាស្ដ្រជំនួស (substitue method) ប្រើព័ត៌មានបានមកពីទីផ្សារនៅក្បែរគ្នា ហើយវិធីសាស្ដ្រតម្លៃពេលវេលា (time method) ផ្អែកលើការចំណាយពេលប្រមូលផល គុណនឹងថ្លៃឱកាសនៃកំលាំងពលកម្មក្នុងមូលដ្ឋាន ។

## លទ្ធផល

### ថ្លៃផលព្រៃឈើ

មានតែវិធីសាស្ដ្រថ្លៃទីផ្សារមូលដ្ឋាន និងវិធីសាស្ដ្រជំនួស ប៉ុណ្ណោះ ដែលអាចប្រើ ដើម្បីប៉ាន់ស្មានថ្លៃផលិតផលបានពីព្រៃឈើទាំងអស់បាន (កែច្នៃរួច និងមិនទាន់កែច្នៃ) ។ ទោះបីវិធីសាស្ដ្រតម្លៃពេលវេលា គេតែងប្រើជាទូទៅសម្រាប់វាយតម្លៃការធ្វើកសិកម្មក្ដី ប៉ុន្ដែវាពិបាកអនុវត្តប្រើជាក់ស្ដែង សម្រាប់វាយតម្លៃផលព្រៃឈើក្នុងតំបន់សិក្សារបស់យើង ។ វិធីសាស្ដ្រទីផ្សារមូលដ្ឋាន មានប្រើជាញឹកញាប់សម្រាប់វាយតម្លៃ ដល់ទៅ ៧១% នៃផលព្រៃឈើសរុប ចំណែកឯ ២៩% ទៀត គេវាយតម្លៃតាមប្រើវិធីសាស្ដ្រជំនួស (តារាង ១) ។ លទ្ធផលស្រាវជ្រាវបង្ហាញថា គ្រួសារគំរូតាងប្រមូលយកផលព្រៃឈើខុសៗគ្នាជាច្រើនយ៉ាង (កែច្នៃរួច និងមិនទាន់កែច្នៃ) ដែលបញ្ជាក់ពីតួនាទីដ៏សំខាន់នៃព្រៃឈើក្នុងការផ្គត់ផ្គង់ និងទ្រទ្រង់ជីវភាពនៅមូលដ្ឋាន ។ ផលព្រៃឈើខ្លះដូចជា សរសៃ និងសត្វព្រៃ-ថនិកសត្វ បង្ហាញនូវគំលាត

ស្តង់ដាយ៉ាងធំ ដោយសារផលព្រៃឈើមុខខ្លះ ត្រូវបានបែងចែកជាអនុក្រុមជាច្រើន ផ្អែកលើគុណភាពខុសៗគ្នា ដូចជា ទំហំ ពូជ ឬផ្នែកនៃរុក្ខជាតិនោះ ។

ផលព្រៃឈើខ្លះ គេនិយមតែក្នុងតំបន់ជាក់លាក់ណាមួយ ហើយខ្លះទៀតគេស្គាល់ជាទូទៅនៅគ្រប់តំបន់ ។ ផលព្រៃឈើចំបងប្រាំមុខ ដែលគេរាយការណ៍ញឹកញាប់បំផុត គឺ អុស ទំពាំង ធ្យូង ឈើហ៊ុប និងឈើអារ ។ ជាទូទៅ ប្រជាជននៅក្នុងតំបន់សិក្សាទាំង៣ តែងធ្វើការប្រមូលអុស និងទំពាំង ។ ធ្យូង និងឫស្សីសម្រាប់ធ្វើបង្គោង (សម្រាប់ឡើងដើមត្នោត) ជាផលព្រៃឈើដែលគេតែងសង្កេតឃើញញឹកញាប់ នៅឃុំសង្កែសាទប ខេត្តកំពង់ស្ពឺ ហើយ ឈើហ៊ុប និងឈើអារ តែងឃើញញឹកញាប់ នៅឃុំទំរីង ខេត្តកំពង់ធំ ។

តារាង១៖ តម្លៃផលព្រៃឈើប្រមូលបានដោយគ្រួសារគំរូតាង (គិតជារៀល)

| ផលព្រៃឈើ | ឯកតានៅមូលដ្ឋាន | បរិមាណ | អប្បបរមា | អតិបរមា | មធ្យម | គំលាតស្តង់ដា | វិធីសាស្រ្ត |
|---|---|---|---|---|---|---|---|
| ផលព្រៃឈើ | | | | | | | |
| សរសរ | ដើម | 38 | 500 | 45000 | 5971 | 8709 | ទីផ្សារមូលដ្ឋាន |
| ឫស្សី | រទេះគោ | 11 | 3000 | 120000 | 43455 | 40636 | ទីផ្សារមូលដ្ឋាន |
| មែកឈើ | រទេះគោ | 10 | 5000 | 50000 | 24100 | 17489 | ទីផ្សារមូលដ្ឋាន |
| ឈើហ៊ុប | ដើម | 108 | 2000 | 300000 | 52847 | 64476 | ទីផ្សារមូលដ្ឋាន |
| បង្គោលរបង | ដើម | 91 | 250 | 15000 | 3095 | 2598 | ទីផ្សារមូលដ្ឋាន |
| ផ្សិត | គីឡូក្រាម | 69 | 500 | 10000 | 3797 | 2375 | ទីផ្សារមូលដ្ឋាន |
| មើមនិងឫសផ្សេងៗ | គីឡូក្រាម | 5 | 2000 | 10000 | 5200 | 3947 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-ថនិកសត្វ | ដុំ | 47 | 1000 | 150000 | 16362 | 32644 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-សត្វល្មូន | ដុំ | 41 | 1000 | 10000 | 4598 | 2584 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-សត្វល្អិត/ជង្គូវ | ចានគោម | 12 | 500 | 3000 | 1500 | 826 | ទីផ្សារមូលដ្ឋាន |
| សត្វព្រៃ-កង្កែប/គីង្គក់/ហ៊ីង | ដុំ | 13 | 50 | 500 | 242 | 161 | ទីផ្សារមូលដ្ឋាន |
| ដើមតាលព្រឹក្ស(អំបូរត្នោត) | ដើម | 38 | 100 | 250 | 201 | 39 | ទីផ្សារមូលដ្ឋាន |
| គមតាលព្រឹក្ស | គម | 36 | 100 | 500 | 265 | 128 | ទីផ្សារមូលដ្ឋាន |
| ទំពាំង | គីឡូក្រាម | 295 | 200 | 2500 | 864 | 577 | ទីផ្សារមូលដ្ឋាន |
| ក្តាម ខ្យង កំពឹស បង្កង | គីឡូក្រាម | 80 | 300 | 10000 | 2591 | 2148 | ទីផ្សារមូលដ្ឋាន |
| អុស | រទេះគោ | 668 | 3000 | 70000 | 23154 | 13533 | ជំនួស |
| វល្លិ | បាច់ | 5 | 1000 | 5000 | 2500 | 1732 | ជំនួស |
| ផ្តៅ | ដើម | 12 | 100 | 1000 | 213 | 255 | ជំនួស |
| ផ្លែឈើព្រៃ | ស្បោង/ការ៉ុង | 5 | 4000 | 25000 | 13800 | 9203 | ជំនួស |
| បន្លែព្រៃ | មួយដៃ | 55 | 200 | 3000 | 867 | 628 | ជំនួស |
| រុក្ខជាតិឱសថ | កំសៀវ | 19 | 1000 | 10000 | 3716 | 2776 | ជំនួស |
| ជ័រឈើ | គីឡូក្រាម | 11 | 300 | 1600 | 927 | 410 | ជំនួស |
| ស្បូវ | រទេះគោ | 9 | 5000 | 60000 | 27000 | 17457 | ជំនួស |
| សត្វព្រៃ-សត្វស្លាប/ប្រជៀវ | ដុំ | 33 | 1000 | 30000 | 4521 | 7286 | ជំនួស |
| ផលព្រៃឈើកែច្នៃរួច | | | | | | | |
| ឈើបន្ទះ | ម៉ែត្រគូប | 101 | 200000 | 3000000 | 748515 | 379294 | ទីផ្សារមូលដ្ឋាន |
| ធ្យូង | ឡ | 262 | 6000 | 1200000 | 322389 | 169047 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីឈើ | ដុំ | 22 | 1500 | 400000 | 70295 | 85903 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីផ្តៅ | ដុំ | 10 | 2500 | 25000 | 8800 | 6642 | ទីផ្សារមូលដ្ឋាន |
| គ្រឿងសង្ហារឹមធ្វើពីឫស្សី | ដុំ | 7 | 300 | 15000 | 5686 | 5324 | ទីផ្សារមូលដ្ឋាន |
| គ្រឿងប្រក់ដំបូល | កណ្តប | 11 | 400 | 1000 | 664 | 196 | ទីផ្សារមូលដ្ឋាន |
| ទំពាំង | គីឡូក្រាម | 10 | 500 | 15000 | 6150 | 5623 | ទីផ្សារមូលដ្ឋាន |

ក្រាហ្វិក ២៖ ប្រាក់ចំណូលគ្រួសារសរុបតាមត្រីមាស




## ប្រាក់ចំណូលគ្រួសារជាមធ្យម

លទ្ធផលស្រាវជ្រាវបង្ហាញថា ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងអង្កេត គឺ ២.០៤៩.០០០រៀល (៥០៦ដុល្លារ) ។ Bruce *et al.* (2004) ក៏រាយការណ៍ពីចំណូលគ្រួសារប្រចាំឆ្នាំជាមធ្យមស្រដៀងគ្នាដែរ គឺ ២.១៧៧.៨២៤រៀល (៥៣៨ដុល្លារ)[២] នៅខេត្តកំពង់ធំ និង ២.០១៩.៩៥២រៀល (៤៩៩ដុល្លារ) នៅខេត្តមណ្ឌលគិរី ។ ក្រុមស្រាវជ្រាវរកឃើញទៀតថា ប្រាក់ចំណូលគ្រួសារ ប្រែប្រួលពីត្រីមាសមួយទៅត្រីមាសមួយ និងទៅតាមរដូវ ។ គ្រួសារនានារកចំណូលបានប្រហែល ៦០០.០០០រៀល (១៤៨ដុល្លារ) ក្នុងពីរត្រីមាសដំបូង ដែលជារដូវប្រាំង (ក្រាហ្វិក ២) ។ ប៉ុន្តែប្រាក់ចំណូលថយចុះមកត្រឹម ៤៥៥.០០០រៀល (១១២ដុល្លារ) ក្នុងត្រីមាសទី៣ និង ៣៨៧.០០០រៀល (៩៦ដុល្លារ) ក្នុងត្រីមាសទី៤ ដែលស្ទើរតែស្ថិតក្នុងរដូវវស្សាទាំងស្រុង ។ ប្រាក់ចំណូលធ្លាក់ទាបក្នុងត្រីមាសទី៣ និងទី៤ ដោយសារកសិករចំណាយពេលភាគច្រើនធ្វើស្រែរបស់ខ្លួន ដូចជា រៀបចំដី ស្ទូង ថែទាំស្រូវ និងច្រូតកាត់ ជាដើម ។ ប៉ុន្តែសកម្មភាពរបស់ពួកគេក្នុងរយៈពេលនោះ វារួមចំណែកបង្កើនប្រាក់ចំណូលក្នុងត្រីមាសទី១ និងទី២ ។

## ចំណែកប្រាក់ចំណូលបានពីព្រៃឈើក្នុងចំណូលគ្រួសារជាមធ្យម

ប្រាក់ចំណូលសរុបទទួលបានពីប្រភពផ្សេងៗ អាចចែកជា ៤ក្រុមសំខាន់ៗ៖ ព្រៃឈើ កសិកម្ម (ដំណាំ និងសត្វចិញ្ចឹម) មជ្ឈដ្ឋានដទៃទៀត និងផ្នែកផ្សេងៗ (ភាគច្រើនជាប្រាក់ឈ្នួលកំលាំងពលកម្ម) (តារាង ២) ។ ប្រាក់ចំណូលបានពីកសិកម្ម (ស្រូវអង្ករ) ជាកត្តារួមចំណែកចំបងដល់ចំណូលសរុបនៅត្រីមាសទី១ គឺស្មើនឹង ៣០២.៤៦៨រៀល ឬ ៥១% នៃចំណូលសរុបប្រចាំត្រីមាស ។ យើងរកឃើញទៀតថា ប្រាក់ឈ្នួលពលកម្ម ជាប្រភពចំណូលចំបងសម្រាប់ត្រីមាសទី១ ទី២ និងទី៣ ។ ម្យ៉ាងទៀត ចំណូលបានពីផលព្រៃឈើ ជាប្រភពចំណូលចំបងទី៣ សម្រាប់គ្រប់ត្រីមាស ដែលបញ្ជាក់ជាថ្មីពីតម្លៃនៃព្រៃឈើក្នុងប្រាក់ចំណូលរកបាន ក៏ដូចជាការរួមចំណែកនៃព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ។ ធនធានព្រៃឈើ មានចំណែកក្នុងចំណូលសរុបប្រចាំត្រីមាសរបស់អ្នកភូមិ ចាប់ពី ១៣% នៅត្រីមាសទី១ រហូតដល់ ៣១% នៅត្រីមាសទី៣ ។

ក្រុមស្រាវជ្រាវ ក៏បានវិភាគពីប្រាក់ចំណូលនៃគ្រួសារ បែងចែកជា ក្រុមបញ្ចភាគ ដោយក្រុមបញ្ចភាគទី១ ជាក្រុម

តារាង ២៖ ចំណូលគ្រួសារប្រចាំត្រីមាសគិតតាមប្រភព (ជារៀល)

| ចំណូលពីមជ្ឈដ្ឋាននីមួយៗ | ត្រីមាសទី១ | | ត្រីមាសទី២ | | ត្រីមាសទី៣ | | ត្រីមាសទី៤ | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | % | មធ្យម | % | មធ្យម | % | មធ្យម | % |
| ព្រៃឈើ | 74928 | 13 | 157948 | 26 | 139908 | 31 | 117791 | 30 |
| កសិកម្ម | 302468 | 51 | 185814 | 30 | 41777 | 9 | 77279 | 20 |
| មជ្ឈដ្ឋានផ្សេងទៀត | 21021 | 4 | 22961 | 4 | 44888 | 10 | 41671 | 11 |
| ផ្សេងៗ (ប្រាក់ឈ្នួល) | 198130 | 33 | 243034 | 40 | 228950 | 50 | 150774 | 39 |
| *សរុប* | *596547* | *100* | *609757* | *100* | *455523* | *100* | *387516* | *100* |

២ ១ដុល្លារ = ៤០៤៨រៀល (អត្រាប្តូរប្រាក់ជាមធ្យមក្នុងអំឡុងពេលសិក្សា ឆ្នាំ២០០៨) ។

ក្រាហ្វិក ៣៖ ចំណែកនៃចំណូលបានពីព្រៃឈើ ក្នុងចំណូលគ្រួសារសរុប គិតតាមក្រុមបញ្ចភាគប្រាក់ចំណូល




មានចំណូលទាបជាងគេ ។ ក្រាហ្វិក ៣ បង្ហាញថា ប្រាក់ចំណូលពីព្រៃឈើ រួមចំណែក ២៤% ក្នុងចំណូលសរុបនៃគ្រួសារមានចំណូលទាប ។ ចំណូលពីព្រៃឈើ រួមចំណែក ២៦% ក្នុងចំណូលសរុប នៃគ្រួសារមានចំណូលមធ្យម ដែលបង្ហាញថា គ្រួសារក្នុងក្រុមនេះ ពឹងផ្អែកលើចំណូលបានពីធនធានព្រៃឈើច្រើនជាងក្រុមមានប្រាក់ចំណូលទាប ។ រឿងនេះប្រហែលមកពីគ្រួសារមានចំណូលមធ្យម គេមានឧបករណ៍ និងមធ្យោបាយល្អជាង សម្រាប់ការប្រមូលផល និងការដឹកជញ្ជូនផលព្រៃឈើ ដូចជា ឧបករណ៍កាប់ឈើ រទេះគោ ឬក្របី ដែលជួយឲ្យពួកគេប្រមូលធនធានព្រៃឈើបានច្រើនជាង ។

ក្រុមទី៥ (ឬក្រុមមានចំណូលខ្ពស់បំផុត) និងក្រុមមានចំណូលទាបបំផុត ទទួលបានចំណូលពីផលព្រៃឈើ គិតជាភាគរយនៃប្រាក់ចំណូលសរុប ស្ទើរតែដូចគ្នា គឺ ប្រមាណ ២៤% ។ ចំណូលពីព្រៃឈើ មានចំណែកតូចនៅក្នុងប្រាក់ចំណូលសរុបរបស់គ្រួសារមានចំណូលទាបបំផុត ដោយសារជាសំខាន់ ពួកគេខ្វះឧបករណ៍ និងមធ្យោបាយដឹកជញ្ជូន ដែលធ្វើឲ្យពួកគេអាចប្រមូលផលព្រៃឈើបានតិច ។

ទោះបី ក្រុមចំណូលខ្ពស់បំផុត និងក្រុមចំណូលទាបបំផុត មានកម្រិតភាគរយប្រហាក់ប្រហែលគ្នា នៃចំណូលពីព្រៃឈើនៅក្នុងចំណូលសរុបក្តី ប៉ុន្តែបើគិតជាទឹកប្រាក់ បរិមាណផលពីព្រៃឈើរបស់ក្រុមចំណូលខ្ពស់បំផុត វាមានចំនួនច្រើនជាងបរិមាណផលពីព្រៃឈើ ដែលក្រុមចំណូលមធ្យម និងក្រុមចំណូលទាបបំផុតរកបាន ពីព្រោះក្រុមចំណូលខ្ពស់ គេមានប្រភពចំណូលច្រើន ព្រមទាំងមានមធ្យោបាយដឹកជញ្ជូន ឧបករណ៍ប្រមូលផល និងទ្រព្យសកម្មផ្សេងទៀតល្អជាង ដែលអាចឲ្យពួកគេទាញផលចំណេញបានច្រើនពីធនធានព្រៃឈើ ។

ការសិក្សារបស់ Hansen and Neth (2006) បង្ហាញថា គ្រួសារនានាទទួលបានអត្ថប្រយោជន៍ពីធនធានព្រៃឈើ កាន់តែតិចទៅៗ ។ Hansen and Neth (ibid) រាយការណ៍ថា គ្រួសារចំណូលមធ្យម ទទួលបានចំណូលពីផលនិងអនុផលព្រៃឈើប្រមាណ ៣០% នៃតម្លៃជីវភាពសរុបរបស់ពួកគេ ហើយគ្រួសារក្រីក្រទទួលបាន ៤២% ។ រឿងនេះបណ្តាលមកពីកត្តាជាច្រើន ដូចជា ការប្រែប្រួលប្រភពចំណូល ឬការថយចុះធនធានព្រៃឈើ ។

## សេចក្តីសន្និដ្ឋាន

តម្លៃនៃផលព្រៃឈើ អាចប៉ាន់ស្មានតាមរយៈវិធីសាស្ត្រថ្លៃលក់នៅកសិដ្ឋាន (ទីផ្សារមូលដ្ឋាន) និងវិធីសាស្ត្រជំនួស ។ វិធីសាស្ត្រថ្លៃលក់នៅកសិដ្ឋាន ផ្តល់តួលេខប៉ាន់ស្មានត្រឹមត្រូវជាងអំពីតម្លៃផលព្រៃឈើ រីឯវិធីសាស្ត្រជំនួស ផ្តល់តួលេខប៉ាន់ស្មានច្បោលៗជាង ។

ការវាយតម្លៃជាទឹកប្រាក់ នូវធនធានព្រៃឈើដែលអ្នកភូមិប្រើ (លក់ដូរ និងប្រើប្រាស់) វាចាំបាច់ណាស់ ដើម្បីយល់ដឹងកាន់តែប្រសើរ ពីអត្ថប្រយោជន៍នៃធនធានព្រៃឈើចំពោះជីវភាពនៅមូលដ្ឋាន ។ ប៉ុន្តែការវាយតម្លៃហ្មត់ចត់ទាមទារពេលវេលាច្រើន ដើម្បីចម្រាញ់យកព័ត៌មាន និងទិន្នន័យដែលប្រមូលបាន ដោយការប្រើវិធីសាស្ត្រជំនួស ។ ម៉្យាងទៀត ការវាយតម្លៃផលព្រៃឈើតាមថ្លៃទីផ្សារនៅមូលដ្ឋានដែលគេរាយការណ៍ឡើង ជួយឲ្យយើងមើលឃើញបានធំទូលាយពីតម្លៃផលព្រៃឈើ ដែលរួមចំណែកក្នុងចំណូលគ្រួសារ និងអាចឲ្យយើងប៉ាន់ស្មានបានពីការរួមចំណែកនៃធនធានព្រៃឈើក្នុងការកាត់បន្ថយភាពក្រីក្រ ។

ធនធានព្រៃឈើ ជាប្រភពចំណូលដ៏មានសំខាន់មួយ ។ ក្នុងការសិក្សានេះ ធនធានព្រៃឈើរួមចំណែក ២៦% ក្នុងចំណូលគ្រួសារសរុប សម្រាប់គ្រួសារក្នុងក្រុមចំណូលមធ្យម និង ២៤% សម្រាប់ក្រុមចំណូលទាប ។ គ្រួសារចំណូលខ្ពស់ ក៏

(តទៅទំព័រ ១៣)

# គណនេយ្យភាពនៅកម្ពុជា៖ ទ្រឹស្តី និងការអនុវត្ត[១]

## សេចក្តីផ្តើម

សព្វថ្ងៃ គេឃើញពាក្យគណនេយ្យភាពលេចឡើងជាញឹកញាប់នៅក្នុងឯកសារផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយជាដៃគូអភិវឌ្ឍន៍នានា ។ ប៉ុន្តែយើងសង្កេតឃើញថា មានមនុស្សជាច្រើន ទាំងប្រជាជននិងមន្ត្រី ទាំងក្នុងនិងក្រៅជួររដ្ឋាភិបាល នៅស្រពិចស្រពិលអំពីអត្ថន័យពាក្យថ្មីនេះ ហើយការយកមកប្រើប្រាស់ ច្រើនផ្អែកតាមទ្រឹស្តីរដ្ឋបាលសាធារណៈ និងអភិបាលកិច្ចនៅបស្ចិមប្រទេស ដោយមិនទាន់បានឆ្លុះបញ្ចាំងឱ្យជិតដល់អំពីបរិបទពិតប្រាកដនៅកម្ពុជាទេ ។

អត្ថបទនេះ មានបំណង (១) បំភ្លឺពីនិយមន័យពាក្យគណនេយ្យភាព (២) ធ្វើការបកស្រាយ និងចែករំលែកគំនិតទាក់ទងនឹងទ្រឹស្តីសំខាន់ៗមួយចំនួន ដែលបានលើកឡើងស្តីពីវិធីសាស្ត្រ សម្រាប់ធានាឱ្យមានគណនេយ្យភាពនៅក្នុងអភិបាលកិច្ចសាធារណៈ និង (៣)ផ្តល់ជាគំនិតមួយចំនួនទាក់ទងនឹងការបន្តសិក្សាស្រាវជ្រាវអំពី គណនេយ្យភាពនៅក្នុងបរិបទកម្ពុជា ។

## អ្វីទៅជា "គណនេយ្យភាព"?

គណនេយ្យភាព ជាវាក្យស័ព្ទមួយយ៉ាងសំខាន់នៅក្នុងវិទ្យាសាស្ត្រនយោបាយ និងគណនេយ្យហិរញ្ញវត្ថុ ។ ប៉ុន្តែថ្មីៗនេះ គេបានយកវាទៅប្រើនៅក្នុងស្ថានភាពផ្សេងៗគ្នា ហើយឱ្យនិយមន័យផ្សេងៗគ្នា ដែលនាំឱ្យមានការភាន់ច្រឡំមួយចំនួន (Linberg 2009; Mulgan 2000) ។ នៅកម្ពុជា ចាប់តាំងពីមានការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អ ពាក្យគណនេយ្យភាពនេះកាន់តែទទួលបាននូវប្រជាប្រិយភាព ។ ប៉ុន្តែជារឿយៗ អ្នកស្តាប់ខ្លះ មានការស្រពិចស្រពិលពីអត្ថន័យពិត ឬក៏យល់ច្រឡំគណនេយ្យភាព ជាមួយនឹងកាងារចុះបញ្ជីគណនេយ្យ ។ ថ្មីៗនេះ មានមនុស្សកាន់តែច្រើនចាប់ផ្តើមយល់ថា គណនេយ្យភាពមានន័យដូចគ្នានឹងការទទួលខុសត្រូវ ។ ដើម្បីជាការបំភ្លឺ អត្ថបទនេះផ្តល់ការបកស្រាយដូចតទៅ៖

ដើម្បីជៀសវាងការភាន់ច្រឡំ គេគួរយល់ឲ្យច្បាស់លើទិដ្ឋភាពពីរផ្សេងគ្នា៖ (១) ធាតុសំខាន់ៗ និងប្រភេទនៃគណនេយ្យភាព និង (២) ប្រព័ន្ធអភិបាលកិច្ចដែលត្រូវមានជាចាំបាច់ ដើម្បីធានាបាននូវគណនេយ្យភាព (Linberg 2009) ។ ក្នុងទិដ្ឋភាពទី១ គណនេយ្យភាពត្រូវមានធាតុសំខាន់ចំនួន ៥ ដូចខាងក្រោម៖

(១) បុគ្គល ឬស្ថាប័នដែលត្រូវមានគណនេយ្យភាព
(២) មុខងារ តួនាទី និងដែននៃការទទួលខុសត្រូវ ដែលបុគ្គល ឬស្ថាប័ននោះ ត្រូវមានគណនេយ្យភាព
(៣) បុគ្គល ឬស្ថាប័នផ្សេងទៀត ដែលមានតួនាទីទាមទារគណនេយ្យភាព អំពីបុគ្គល ឬស្ថាប័នខាងលើ
(៤) សិទ្ធិរបស់បុគ្គល ឬស្ថាប័នទី២ ក្នុងការទាមទារឱ្យបុគ្គល ឬស្ថាប័នទី១ ត្រូវផ្តល់ព័ត៌មាន និងពន្យល់ពីអ្វីដែលខ្លួនបានធ្វើ ទាក់ទងនឹងដែននៃការទទួលខុសត្រូវដែលបានប្រគល់ឱ្យ
(៥) សិទ្ធិរបស់បុគ្គល ឬស្ថាប័នទី២ ក្នុងការផ្តល់រង្វាន់ ឬដាក់ទោសទណ្ឌដល់បុគ្គល ឬស្ថាប័នទី១ ផ្អែកតាមការបំពេញការងារ ក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន ។

គណនេយ្យភាព អាចមានជាប្រភេទ នយោបាយ សង្គមកិច្ច ហិរញ្ញវត្ថុ ច្បាប់ ។ល។ គណនេយ្យភាពប្រភេទនីមួយៗ ត្រូវបានកំណត់ទៅតាមវិធាន និងស្តង់ដារជាប់ពាក់ព័ន្ធ ។ ឧទាហរណ៍ គណនេយ្យភាពតាមផ្លូវច្បាប់ ត្រូវអនុលោមទៅតាមវិធានច្បាប់ដែលមាន រីឯគណនេយ្យភាពហិរញ្ញវត្ថុ ត្រូវផ្អែកទៅតាមវិធាននៃការគ្រប់គ្រងហិរញ្ញវត្ថុ ។ល។ វិធាន និងស្តង់ដារទាំងនេះ ក្នុងករណីខ្លះ មិនចាំបាច់មានចែងជាលាយលក្ខណ៍អក្សរទេ ។ វិធាននិងទម្លាប់ខ្លះ ទោះមិនមែនជាច្បាប់ ក៏អាចមានឥទ្ធិពលខ្លាំងជាងច្បាប់ជាលាយលក្ខណ៍អក្សរទៅទៀត ។

តាមការសង្កេត ក្នុងការពិភាក្សាគោលនយោបាយនៅកម្ពុជា នៅពេលមានប្រើពាក្យគណនេយ្យភាព គេមិនសូវបានកំណត់ច្បាស់ទេ អំពីប្រភេទគណនេយ្យភាពដែលកំពុងផ្តោតលើ គឺថា តើតួអង្គណា មានគណនេយ្យភាពចំពោះតួអង្គណា? ទៅលើដែននៃការទទួលខុសត្រូវណា? ត្រូវប្រើវិធាន ស្តង់ដារ និងប្រព័ន្ធអភិបាលកិច្ចអ្វី ដើម្បីធានាឱ្យមានគណនេយ្យភាពដែលចង់បាន? រឿងនេះជាមូលហេតុមួយ ដែលនាំឱ្យមានការយល់ច្រឡំក្នុងចំណោមអ្នកចូលរួមក្នុងការពិភាក្សា ។

ប៉ុន្តែក្នុងករណីខ្លះ អ្នកពិភាក្សាមានការលំបាកនឹងបែងចែកឱ្យច្បាស់ ទៅតាមចំណុចនីមួយៗដូចខាងលើនេះ ដោយសារនៅក្នុងវិស័យសាធារណៈ គណនេយ្យភាពច្រើនប្រភេទអាចនៅលាយឡំគ្នា ហើយត្រូវមានវិធានច្រើនយ៉ាង ដើម្បីធានាឱ្យបានគណនេយ្យភាពទាំងនោះ ។ ម្យ៉ាងទៀត ក្នុងវិស័យសាធារណៈ មានតួអង្គច្រើននាក់ ហើយម្នាក់ៗអាចមានគណនេយ្យភាពក្នុងដែនការទទួលខុសត្រូវផ្សេងៗគ្នាក្នុងពេលតែមួយ និងត្រូវឆ្លើយតបចំពោះ បុគ្គល និងស្ថាប័នផ្សេងៗ លើសពីមួយ ។ ផ្នែកខាងក្រោម ជាការពិភាក្សាលើទ្រឹស្តីសំខាន់ៗមួយចំនួន ដែលអាចជួយបំភ្លឺពីភាពស្មុគស្មាញទាំងនេះ ។

## ទ្រឹស្តីសកលស្តីពីការពង្រឹងគណនេយ្យភាព

គណនេយ្យភាព មានច្រើនប្រភេទក្នុងវិស័យសាធារណៈ ហើយសំខាន់ជាងគេ គឺ គណនេយ្យភាពនយោបាយ ដែលមន្ត្រីជាប់ឆ្នោត (ឬហៅថាមន្ត្រីនយោបាយ) ត្រូវមានចំពោះប្រជាជន

---

១ អត្ថបទនេះតាក់តែងឡើងដោយ លោក ប៉ក់ គឹមជឿន និងលោក គ្រុយ វីរៈ ជាអ្នកស្រាវជ្រាវនៅ CDRI ។

ជាម្ចាស់ឆ្នោត ។ ប៉ុន្តែមន្ត្រីនយោបាយពុំមានមធ្យោបាយឆ្លើយតបទៅនឹងរាល់តម្រូវការរបស់ប្រជាជននោះទេ ដូច្នេះ ត្រូវមានការបង្កើតជាក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដែលជាអ្នកបច្ចេកទេសអនុវត្តការផ្តល់សេវាដល់ប្រជាជន និងការងារផ្សេងទៀត ដែលរដ្ឋគួរធ្វើ ។ ក្នុងន័យនេះ មន្ត្រីបច្ចេកទេសត្រូវមានគណនេយ្យភាពចំពោះមន្ត្រីនយោបាយ ដែលគេហៅថា គណនេយ្យភាពរដ្ឋបាល ។

ទាំងក្នុងន័យនយោបាយ និងរដ្ឋបាល ធាតុទាំង ៥ នៃគណនេយ្យភាពនៅរក្សាដដែល ដូចជា៖ (១) អ្នកដែលត្រូវមានគណនេយ្យភាព (២) អ្នកដែលមានសិទ្ធិទាមទារឱ្យអ្នកទី១ត្រូវមានគណនេយ្យភាព (៣) ការទទួលខុសត្រូវ ដែលអ្នកទី១ត្រូវមានគណនេយ្យភាព (៤) ព័ត៌មានអំពីការអនុវត្តរបស់ជនដែលត្រូវមានគណនេយ្យភាព និង (៥) ការផ្តល់រង្វាន់ ឬការដាក់ទោសទណ្ឌទៅតាមអ្វីដែលអ្នកទី១ បានធ្វើ ។ ប៉ុន្តែរឿងថាតើប្រព័ន្ធអភិបាលកិច្ចមួយណាដែលគួរមកយកប្រើ ដើម្បីធានាឱ្យមានគណនេយ្យភាព វាជាចំណោទមួយដ៏ស្មុគស្មាញ ។ នៅខាងក្រោម គឺជាទ្រឹស្តីសំខាន់ៗមួយចំនួន ដែលឆ្លើយនឹងសំណួរនេះ ។

ទ្រឹស្តីទី១ ឈ្មោះថា ទ្រឹស្តីគោលក្នុងរដ្ឋបាលសាធារណៈ ហៅកាត់ថា TPA និងរកឃើញដោយ សង្គមវិទូអាឡឺម៉ង់ឈ្មោះ Weber នៅដើមសតវត្សរ៍ទី២០ ។ ទ្រឹស្តីនេះចែងថា ដើម្បីឱ្យរដ្ឋមួយ អាចបម្រើប្រជាជនបាន រដ្ឋនោះត្រូវមានប្រព័ន្ធរដ្ឋបាលមួយដែលអនុលោមតាមច្បាប់ និងដែលឡូស៊ិក ។ នៅក្នុងប្រព័ន្ធនោះ ការងារនយោបាយ និងបច្ចេកទេស ត្រូវបែងចែកឲ្យដាច់ពីគ្នា ហើយអ្នកតាក់តែងគោលនយោបាយ មិនត្រូវទទួលរងឥទ្ធិពលនយោបាយ ពីគណបក្សណាមួយឡើយ ។ នៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈនេះ មានអនុប្រព័ន្ធជាច្រើនទៀត ដូចជា ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយទាំងអស់នេះត្រូវដើរតាមច្បាប់ និងវិធានជាសកលមួយ ។ មន្ត្រីនៅថ្នាក់ក្រោម ត្រូវមានគណនេយ្យភាពចំពោះមន្ត្រីដែលមានឋានានុក្រមខ្ពស់ជាង ដោយយោងតាមក្រឹត្យក្រមរដ្ឋបាលជាធរមាន ។ គណនេយ្យភាពក្នុងប្រព័ន្ធនេះផ្តោតជាសំខាន់ទៅលើអនុលោមភាពរបស់មន្ត្រីទាំងឡាយ ក្នុងការអនុវត្តការងាររបស់ខ្លួនទៅតាមច្បាប់ និងក្រឹត្យក្រម ជាធរមាន (Weber 1978) ។

ទ្រឹស្តីខាងលើត្រូវបានគេទិតៀនថា មានលក្ខណៈរឹងកំព្រឹស និងមជ្ឈការខ្លាំង ។ ដើម្បីបំពេញលើចំណុចខ្វះខាតទាំងនេះ ទ្រឹស្តីមួយទៀតឈ្មោះថា ការគ្រប់គ្រងវិស័យសាធារណៈបែបថ្មី ហៅកាត់ថា NPM ត្រូវបានតាក់តែងឡើងនៅទសវត្សរ៍ ១៩៥០ និង ១៩៦០ ដែលគាំទ្រឱ្យមានការគ្រប់គ្រងតាមបែបវិមជ្ឈការ និងផ្តល់ឱ្យមន្ត្រីរាជការនូវឆន្ទានុសិទ្ធិ ភាពបត់បែន និងធនធានគ្រប់គ្រាន់ ក្នុងការអនុវត្តការងាររបស់ខ្លួន ។ ទ្រឹស្តីនេះអះអាងថា ទាល់តែធ្វើបែបនេះទើបពួកគេអាចបំពេញតម្រូវការរបស់ប្រជាជនបាន ។ យោងតាម NPM គេបានជម្រុញសកម្មភាពកំណែទម្រង់សាធារណៈមួយចំនួន ដូចជា ការធ្វើឯកជនភាវូបនីយកម្ម ការជួលឱ្យភាគីក្រៅរដ្ឋាភិបាលបំពេញការងារដែលជាទំនួលខុសត្រូវរបស់រដ្ឋ ការគ្រប់គ្រងផ្អែកតាមលទ្ធផលការងារ ។ល។

តាមទ្រឹស្តីនេះ គណនេយ្យភាពកើតមាន នៅពេលមន្ត្រីម្នាក់សម្រេចបានលទ្ធផលការងារដែលគេរំពឹងទុក ដោយមិនគ្រាន់តែសង្កត់ធ្ងន់ ទៅលើអនុលោមភាពតាមច្បាប់ជាធរមានប៉ុណ្ណោះទេ ។ ដូច្នេះ ការងារសំខាន់ គឺ ទី១ ត្រូវកំណត់ឱ្យបាននូវប្រព័ន្ធលើកទឹកចិត្តមួយសម្រាប់មន្ត្រី និងទី២ ត្រូវមានវិធានការគ្រប់គ្រាន់ ដើម្បីធានាថា មន្ត្រីទាំងនោះមិនរំលោភលើតួនាទី សិទ្ធិអំណាច និងធនធានដែលប្រគល់ឱ្យ (Minougue 2001) ។

នៅដើមទសវត្សរ៍១៩៨០ ទ្រឹស្តីមួយទៀតឈ្មោះថា ប្រព័ន្ធស្ថាប័នថ្មី ហៅកាត់ថា NI បានលេចឡើង ។ ក្នុងទ្រឹស្តីពាក្យស្ថាប័ននេះ មានអត្ថន័យធំទូលាយ និងអរូបី ដោយមិនគ្រាន់តែសំដៅលើអង្គភាព ឬអង្គការចាត់តាំងមួយនោះទេ ប៉ុន្តែមានន័យស្មើនឹង ក្បួន ច្បាប់ វិធាន ទម្លាប់នានា ដែលអាចចង និងកម្រិតសកម្មភាពរបស់មនុស្ស ។ ទ្រឹស្តី NI នេះចែងថា ដើម្បីឱ្យវិស័យសាធារណៈ និងប្រព័ន្ធសេដ្ឋកិច្ចមួយ អាចបោះជំហានទៅមុខបាន គេត្រូវមានស្ថាប័ន (ពោលគឺ ក្បួន ច្បាប់ វិធាន ទម្លាប់) ដែលត្រឹមត្រូវ (North 1990) ។

ទ្រឹស្តីនេះ ស្តាប់ទៅហាក់មានវិសាលភាពយ៉ាងធំធេង ។ តាមខ្លឹមសារដូចខាងលើ ទ្រឹស្តីនេះ ហាក់គ្មានអ្វីទាស់ខុសទេ ប៉ុន្តែមានគេទិតៀនថា វាទូលំទូលាយពេក រីឯនិយមន័យនៃពាក្យស្ថាប័ន ក៏ហាក់គ្មានអ្វីច្បាស់លាស់ ហើយក្នុងការប្រើប្រាស់ក៏មិនមានសង្គតិភាព ។ ទ្រឹស្តីនេះ ហាក់មិនមានចែងច្បាស់អំពីគណនេយ្យភាពទេ ប៉ុន្តែគេសង្កេតឃើញថា ម្ចាស់ជំនួយជាច្រើននៅលោកខាងលិច បានផ្អែកលើវាក្នុងការផ្តួចផ្តើមគំនិតថ្មីៗទាក់ទងនឹងអភិបាលកិច្ចល្អ ដូចមានរៀបរាប់នៅខាងក្រោម៖

- ទី១ គឺ ទ្រឹស្តីអំពីតួនាទីរបស់រដ្ឋ នៅក្នុងការអភិវឌ្ឍប្រទេស ដែលហៅថា ទ្រឹស្តីរដ្ឋមានសមត្ថភាព ដូចមានចែងក្នុងរបាយការណ៍អភិវឌ្ឍពិភពលោកឆ្នាំ១៩៩៧។នៅទសវត្សរ៍១៩៨០ និង ១៩៩០ អង្គការម្ចាស់ជំនួយជាច្រើន បានទិតៀនថា រដ្ឋ (សំដៅដល់រដ្ឋាភិបាល) គឺជាប្រភពបញ្ហានាំឱ្យការអភិវឌ្ឍដើរយឺត ដូច្នេះ តួនាទីនិងទំហំរបស់រដ្ឋ ត្រូវតែកាត់បន្ថយ ដើម្បីបើកផ្លូវឱ្យវិស័យឯកជន ចូលបំពេញតួនាទីជំនួសភាគច្រើន ដោយគេអះអាងថា វិស័យឯកជនអាចមានប្រសិទ្ធិភាពក្នុងការងារខ្ពស់ជាង ។ ក្រោយមក ទ្រឹស្តីរដ្ឋមានសមត្ថភាព បានចាប់យកផ្លូវកណ្តាល ដោយអះអាងថា រដ្ឋត្រូវមានតួនាទីក្នុងការអភិវឌ្ឍ តែមិនមែនទៅជំនួសវិស័យឯកជននោះទេ ប៉ុន្តែត្រូវជួយគាំទ្រដល់វិស័យឯកជនវិញ ។ បើនិយាយពីគណនេយ្យភាព ទ្រឹស្តីនេះ ផ្តោតលើរូបភាពរួមពោលគឺ គណនេយ្យភាពរវាងរដ្ឋ និងប្រជាជន ក្នុងប្រទេសមួយតែម្តង ។ ទន្ទឹមគ្នានឹងការទទួលស្គាល់តួនាទីរបស់វិស័យឯកជន ទ្រឹស្តីនេះលើកឡើងថា រដ្ឋមិនអាចគេចវេះពីគណនេយ្យភាព ក្នុងការផ្តល់នូវសេវាកម្មបឋមដល់ប្រជាជនបានឡើយ (World Bank 1997) ។

ដើម្បីមានគណនេយ្យភាព រដ្ឋត្រូវបណ្ដុះសមត្ថភាព ៣ យ៉ាងគឺ (១) សមត្ថភាពក្នុងការតាក់តែងគោលនយោបាយ ឲ្យសមស្របតាមតម្រូវការរបស់ប្រជាជន, (២) សមត្ថភាពក្នុងការអនុវត្តគោលនយោបាយទាំងនោះ ប្រកបដោយប្រសិទ្ធិភាព និង (៣) សមត្ថភាពក្នុងការជម្រុញឱ្យប្រជាជនចូលរួមក្នុងការទាមទារពីរដ្ឋ នូវគណនេយ្យភាពលើការងារក្នុងចំណុច(១) និង(២) ។

- គេបានយកទ្រឹស្ដីនេះ មកបំបែក និងបំភ្លឺបន្ថែម នៅក្នុងរបាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ២០០៤ ដែលបង្កើតបានជាទ្រឹស្ដីមួយទៀត ហៅថា គណនេយ្យភាពត្រីកោណ ។ មុំទាំង៣ នៃគណនេយ្យភាពនេះ គឺមានគណនេយ្យភាពរវាង (១) ប្រជាជន និងអ្នកផ្ដល់សេវា (២) អ្នកផ្ដល់សេវា និងអ្នកតាក់តែងគោលនយោបាយ និង (៣) អ្នកតាក់តែងគោលនយោបាយ និងប្រជាជន ។ មុំទី១ ជាផ្លូវកាត់ ផ្ដោតចំតែលើការធ្វើយ៉ាងណា ឲ្យអ្នកផ្ដល់សេវាមានគណនេយ្យភាពចំពោះប្រជាជន រីឯមុំទី២ និងទី៣ គួបគ្នាហៅថា ផ្លូវវាង ដោយហេតុថា ដើម្បីទទួលបានគណនេយ្យភាពលើការផ្ដល់សេវា ប្រជាជនត្រូវធ្វើការទាមទារ តាមរយៈមន្ត្រីជាប់ឆ្នោត ដែលជាអ្នកតាក់តែងគោលនយោបាយ (World Bank 1997) ។

ដើម្បីឱ្យគណនេយ្យភាពត្រីកោណ អាចសម្រេចទៅបាន ត្រូវមានកត្តា ៥ យ៉ាង៖ (១) ការធ្វើប្រតិភូកម្ម (២) ការប្រគល់ធនធាន (៣) ការអនុវត្តការងារ (៤) ព័ត៌មានអំពីការអនុវត្តការងារ និង (៥) ការផ្ដល់រង្វាន់ ឬការដាក់ទោសទណ្ឌ ទៅតាមលទ្ធផលការងារ ។ តាមទ្រឹស្ដីនេះ ឧទាហរណ៍ ប្រសិនបើលោក សុខ ត្រូវមានគណនេយ្យភាពចំពោះការងារអ្វីមួយ ដំបូងគាត់ត្រូវទទួលបានការផ្ទេរមុខងារនិងការទទួលខុសត្រូវច្បាស់លាស់ និងការផ្ទេរធនធានសមរម្យទៅតាមមុខងារនោះ ។ រីឯ លោក សុខ ក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីបំពេញការងារដែរ ។ ស្ថាប័ន ឬបុគ្គលដែលត្រូវទាមទារគណនេយ្យភាពពីលោក សុខ ត្រូវមានព័ត៌មានអំពីអ្វីដែលគាត់បានធ្វើ បើគាត់ធ្វើបានល្អ គួរមានការផ្ដល់រង្វាន់ តែបើមិនបានល្អ ត្រូវដាក់ទោសទណ្ឌតាមស្ថានភាពជាក់ស្ដែង។

- គណនេយ្យភាពត្រីកោណ ជាក្របខ័ណ្ឌមួយសម្រាប់ធ្វើការពិភាក្សាពីទ្រឹស្ដីផ្សេងៗទៀត ទាក់ទងនឹងការលើកកម្ពស់គណនេយ្យភាពក្នុងវិស័យសាធារណៈ ។ ទ្រឹស្ដីដ៏សំខាន់មួយ គឺវិមជ្ឈការ ដែលចែងថា ការផ្ទេរសិទ្ធិនយោបាយ និងរដ្ឋបាល ច្រើនជាងមុន ឱ្យទៅថ្នាក់ក្រោមជាតិនិងមូលដ្ឋាន ធ្វើឱ្យរដ្ឋអាចឆ្លើយតបចំពោះតម្រូវការប្រជាជន បានកាន់តែល្អ គឺបានន័យថា រដ្ឋមានគណនេយ្យភាពល្អចំពោះប្រជាជន ។ សម្រាប់គណនេយ្យភាពត្រីកោណ ការធ្វើវិមជ្ឈការ អាចជួយបង្រួញផ្លូវវាង ព្រោះពេលនោះមន្ត្រីជាប់ឆ្នោតដែលជាអ្នកតាក់តែងគោលនយោបាយ បានខិតទៅជិតនឹងអ្នកទទួលសេវា ។

អ្នកគាំទ្រវិមជ្ឈការ បានអះអាងថា កំណែទម្រង់នេះ នាំឱ្យមានកត្តាទាំង ៥ ដូចបានលើកឡើងខាងលើ ។ ឧទាហរណ៍ បន្ទាប់ពីបានបង្កើតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ តាមទ្រឹស្ដីវិមជ្ឈការ ត្រូវមាន ការផ្ទេរមុខងារ ការផ្ទេរសិទ្ធិក្នុងការប្រមូលពន្ធមូលដ្ឋាន មូលនិធិផ្ទេរពីរដ្ឋបាលថ្នាក់ជាតិផ្ទាល់ និងប្រព័ន្ធគ្រប់គ្រងមួយ ដែលអាចធានាបានថា រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានគណនេយ្យភាពចំពោះថ្នាក់ជាតិផង ចំពោះប្រជាជននៅមូលដ្ឋានផង និងរវាងតួអង្គសំខាន់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិខ្លួនឯងផង (Cheema and Rondinelli 2007) ។ ការងារនេះ គឺជាវិមជ្ឈការហិរញ្ញវត្ថុ ដែលកម្ពុជាបាននិងកំពុងអនុវត្ត ។

- ទ្រឹស្ដីមួយទៀតហៅថា គណនេយ្យភាពសង្គម ជម្រុញឱ្យមានការធានាគណនេយ្យភាព តាមរយៈការផ្ដល់សិទ្ធិអំណាចឲ្យប្រជាជន និងការចូលរួមរបស់សង្គមស៊ីវិល ។ តាមទ្រឹស្ដីនេះ រដ្ឋទំនងជានឹងមានគណនេយ្យភាពច្រើនជាងមុន ប្រសិនបើ ប្រជាជន និងសង្គមស៊ីវិល មានសមត្ថភាព និងការត្រៀមខ្លួនដើម្បីធ្វើការទាមទារ ដូចជា តាមរយៈការបញ្ចេញមតិ ការតវ៉ា ការបង្កើតឱ្យមានការិយាល័យប្រជាពលរដ្ឋ ការចងក្រងជាក្រុម (World Bank 2005) ។

ទ្រឹស្ដីនានាដូចបានរៀបរាប់ខាងលើ ភាគច្រើនចេញមកពីបស្ចិមប្រទេស ជាពិសេសតាមរយៈទីភ្នាក់ងារផ្ដល់ជំនួយរបស់គេ ។ ទ្រឹស្ដីទាំងនេះ មួយផ្នែកកើតចេញពីបទពិសោធន៍ដែលទីភ្នាក់ងារទាំងនោះទទួលបាន តាមការផ្ដល់ជំនួយទៅប្រទេសក្រីក្រ តាំងពីពេលចប់សង្គ្រាមត្រជាក់មក ។ តាមការបកស្រាយខាងលើ គេឃើញថា ទ្រឹស្ដីទាំងនេះមានការផ្លាស់ប្ដូរចុះឡើង ម្ដងសង្កត់ធ្ងន់លើរដ្ឋ និងប្រព័ន្ធរដ្ឋបាលសាធារណៈ ម្ដងងាកទៅផ្ដោតលើវិស័យឯកជន និងក្រោយមក ព្យាយាមស្វែងរកតុល្យភាពរវាងតួអង្គទាំងពីរ ។

ក្នុង ២ទសវត្សរ៍ចុងក្រោយ ការពង្រឹងតួនាទីរបស់រដ្ឋហាក់ទទួលបានការយកចិត្តទុកដាក់ជាប់រហូត និងកាន់តែខ្លាំង ។ ទន្ទឹមគ្នានេះ ការឱ្យតម្លៃទៅលើអភិបាលកិច្ចល្អ ក៏កាន់តែសំខាន់ឡើងដែរ ។ ប៉ុន្តែក្នុងពេលកន្លងមក កំណែទម្រង់អភិបាលកិច្ចល្អ (ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ) នៅតាមប្រទេសក្រីក្រទូទាំងពិភពលោក ហាក់មិនទទួលបានលទ្ធផលគួរជាទីគាប់ចិត្តឡើយ ។ អ្នកជំនាញខ្លះចោទថា រឿងនេះមកពីការធ្វើកំណែទម្រង់មានមហិច្ឆតាធំពេក ចង់កែទម្រង់លើគ្រប់វិស័យ ។ គេផ្ដល់យោបល់ថា ជាជាងសំដៅយកអភិបាលកិច្ចល្អឥតខ្ចោះ គេគួរសំដៅយកត្រឹមតែអភិបាលកិច្ចដែលល្អគ្រប់គ្រាន់មួយបានហើយ (Grindle 2004) ។

ថ្មីៗនេះ ម៉្យាងដោយសារកំណែទម្រង់រដ្ឋបាលសាធារណៈនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន មានភាពយឺតយ៉ាវ និងម៉្យាងទៀត ដោយសារឃើញមានចំណងទាក់ទងគ្នារវាងអភិបាលកិច្ច និងបញ្ហាសន្តិសុខ ទាំងនៅក្នុងប្រទេសនីមួយៗ និងជាអន្តរជាតិ ទ្រឹស្ដីមួយទៀតហៅថា រដ្ឋផុយស្រួយ ក៏បានផុសឡើង (McLoughlin 2010) ។ គេបានឱ្យនិយមន័យរដ្ឋ

ផុយស្រួយ ថាជា រដ្ឋដែលមិនមានលទ្ធភាពឆ្លើយតបចំពោះតម្រូវការរបស់ប្រជាជន ទាំងលើការផ្ដល់សេវាសាធារណៈ សន្តិសុខ និងនីតិរដ្ឋ ។ កង្វះខាតអភិបាលកិច្ចល្អ គឺជាមូលហេតុធ្វើឱ្យរដ្ឋផុយស្រួយ ។ ប៉ុន្តែទ្រឹស្ដីនេះ ត្រូវគេទិតៀនថា ទូលំទូលាយពេក ដោយចង់ដោះស្រាយទាំងបញ្ហាសន្តិសុខផង និងអភិបាលកិច្ចផង ក្នុងពេលជាមួយគ្នា ។ គេរង់ចាំមើលថា តើទ្រឹស្ដីថ្មីនេះនឹងនាំមកនូវគំនិតថ្មីអ្វីខ្លះ សម្រាប់ជាប្រយោជន៍ដល់ការធ្វើកំណែទម្រង់ និងការពង្រឹងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ ។

## ចំណុចខ្លាំង ចំណុចខ្សោយនៃទ្រឹស្ដី និងការអនុវត្តនៅកម្ពុជា

រាល់ទ្រឹស្ដីសំខាន់ៗដូចខាងលើ សុទ្ធតែបានយកមកអនុវត្តនៅកម្ពុជា ។ ឧទាហរណ៍ កេរ្ដិ៍ដំណែលនៃប្រព័ន្ធរដ្ឋបាលសម័យអាណានិគមបារាំង នៅមានបន្តមកដល់សព្វថ្ងៃ តួយ៉ាងដូចជា ការបែងចែកក្រសួង ស្ថាប័ន ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ សហលក្ខន្តិកៈមន្ត្រីរាជការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ល។ ទាំងអស់នេះ ជាឧទាហរណ៍ជាក់ស្ដែងនៃការយកមកអនុវត្តនូវទ្រឹស្ដី TPA នៅកម្ពុជា ។ ចំណែកឯ NPM វិញ មានយកមកអនុវត្តក្នុងរូបភាពនៃ ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ការចុះកិច្ចសន្យាឱ្យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើការផ្ដល់សេវាសុខាភិបាល និងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការប្រើថវិកាតាមកម្មវិធី ។ល។

ទ្រឹស្ដីផ្សេងទៀត ដូចជា រដ្ឋមានសមត្ថភាព វិមជ្ឈការ និងគណនេយ្យភាពសង្គម កំពុងមានអនុវត្តរាល់ថ្ងៃនៅកម្ពុជា ។ ឧទាហរណ៍ជាក់ស្ដែង មានដូចជា ការអនុវត្តកំណែទម្រង់ប្រព័ន្ធបោះឆ្នោត រដ្ឋបាលសាធារណៈ ហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការ ការលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិល ការបង្កើតឱ្យមានការិយាល័យប្រជាពលរដ្ឋនៅក្រុងបាត់ដំបង និងក្រុងសៀមរាប (Thon *et. al.* 2010) ។ ប៉ុន្តែគេសង្កេតឃើញថា អ្នកស្ដាប់ភាគច្រើន មានការលំបាកយល់ និងការភ័ន្តច្រឡំ នៅពេលព្យាយាម ផ្សារភ្ជាប់ទ្រឹស្ដី និងសកម្មភាពកំណែទម្រង់ទាំងនេះទៅនឹងពាក្យថា គណនេយ្យភាព ។

មានមូលហេតុពីរ ដែលបង្កការភ័ន្តច្រឡំដូចខាងលើ ។ ទីមួយ គឺ ការមិនបានពន្យល់ឱ្យច្បាស់ ពីភាពខុសគ្នារវាងគណនេយ្យភាព ហើយនិងមធ្យោបាយដែលត្រូវមាន ដើម្បីធានាឱ្យបានគណនេយ្យភាព ។ សម្រាប់អ្នកស្ដាប់ភាគច្រើននៅកម្ពុជា គណនេយ្យភាព គឺជាលទ្ធផលដែលគេរំពឹងចង់បាន ។ ចំណែកឯនៅក្នុងទ្រឹស្ដីសកល គណនេយ្យភាព គឺជា លទ្ធផលផង និងជាដំណើរការ ឬមធ្យោបាយសម្រាប់ឱ្យមានលទ្ធផលនោះផង ។ ដើម្បីជៀសវាងការភ័ន្តច្រឡំ គួរបញ្ជាក់បន្ថែមថា រាល់ទ្រឹស្ដី និងកំណែទម្រង់ដែលបានអនុវត្ត គឺជាដំណើរការ ឬមធ្យោបាយ ដើម្បីឱ្យមានគណនេយ្យភាព ។ ម្យ៉ាងទៀត មិនថាទ្រឹស្ដីណា ឬសកម្មភាពកំណែទម្រង់ណា ត្រូវបានដាក់អនុវត្តនោះទេ ខ្លឹមសារ និងធាតុរបស់គណនេយ្យភាព នៅរក្សាដដែល ដូចបានរៀបរាប់ក្នុងផ្នែកទី២ នៅខាងលើ ។

មូលហេតុទីពីរ ដែលនាំឱ្យមានការភ័ន្តច្រឡំ គឺការមិនបានបញ្ជាក់ពីប្រភេទនៃគណនេយ្យភាព ដែលកំពុងពិភាក្សា ។ នៅក្នុងសង្គមប្រជាធិបតេយ្យ គណនេយ្យភាពដែលទូលំទូលាយជាងគេ គឺ គណនេយ្យភាពនយោបាយ រវាងមន្ត្រីជាប់ឆ្នោត និងម្ចាស់ឆ្នោត ។ ប៉ុន្តែគេក៏អាចយកគណនេយ្យភាពមកប្រើក្នុងន័យជាក់លាក់ និងតូចចង្អៀតជាងនេះបានដែរ ឧទាហរណ៍ ដូចជា គណនេយ្យភាព រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាងមន្ត្រីថ្នាក់ខ្ពស់ និងមន្ត្រីក្រោមឱវាទ ឬក៏គណនេយ្យភាពរវាងសាលារៀន និងមាតាបិតាសិស្ស ។ល។

ចំណុចសំខាន់គួរពិចារណាមួយទៀត គឺ រាល់ទ្រឹស្ដីដូចបានរៀបរាប់ខាងលើ មានប្រភពចេញមកពីបស្ចឹមប្រទេស ដូច្នេះ ពេលខ្លះមិនអាចឆ្លុះបញ្ចាំងបានគ្រប់ជ្រុងជ្រោយ អំពីគណនេយ្យភាពនៅកម្ពុជាទេ ។ រាល់សកម្មភាពកំណែទម្រង់ដែលបានអនុវត្តកន្លងមក ក៏សុទ្ធតែមានបង្កប់នូវការសន្មតថា ប្រទេសមួយ អាចមានគណនេយ្យភាពបាន លុះត្រាដើរតាមលម្អានរបស់លោកខាងលិច ។ ឈរលើការសន្មតនេះ កំណែទម្រង់ភាគច្រើនបានកំណត់ថា ការពង្រឹងគណនេយ្យភាព ជាការងារមួយអាចសម្រេចបាន ប្រសិនបើប្រព័ន្ធអភិបាលកិច្ចផ្លូវការរបស់រដ្ឋ បានរៀបចំឡើងទៅតាមលក្ខណៈបច្ចេកទេស ដែលដើរតាមគំរូរបស់លោកខាងលិច ។ ការកំណត់បែបនេះ មិនសូវប្រាកដនិយមទេ ព្រោះថា ការពង្រឹងគណនេយ្យភាពក្នុងវិស័យសាធារណៈ គឺជាការងារបច្ចេកទេសផង និងនយោបាយផង ដែលមិនផ្អែកទាំងស្រុង ទៅលើច្បាប់គ្រប់គ្រងរដ្ឋជាធរមាននោះទេ (ឧ. រដ្ឋធម្មនុញ្ញ) ប៉ុន្តែទៅលើទំនាក់ទំនងរវាងបុគ្គល និងក្រុមអ្នកមានអំណាច ទៅលើទម្លាប់និងផ្នត់គំនិតរបស់មនុស្សក្នុងសង្គមទាំងមូលផងដែរ ហើយទាំងអស់នេះ សុទ្ធតែជាកត្តាកំណត់ថា អ្វីទៅគណនេយ្យភាព? គណនេយ្យភាពកើតមានពេលណា? ដោយសារអ្វី? ។ ដើម្បីយល់ដឹងពីកត្តាដែលមិនមានចែងក្នុងច្បាប់ទាំងនេះ ត្រូវមានទ្រឹស្ដីមួយផ្សេងទៀតជាជំនួយស្មារតី ។

## គណនេយ្យភាព និងទ្រឹស្ដីអំពីបរិវារកិច្ច

ការពិភាក្សានៅខាងលើ ផ្ដោតលើគណនេយ្យភាពអនុលោមតាមច្បាប់ និងវិធានជាផ្លូវការដាក់ចេញដោយរដ្ឋាភិបាល ។ ប៉ុន្តែ គណនេយ្យភាពពុំមែនសុទ្ធតែកំណត់តាមអ្វីដែលមានចែងជាផ្លូវការនោះទេ ។ ពេលខ្លះ កត្តាដែលគ្មានចែងក្នុងច្បាប់ វាមានឥទ្ធិពលខ្លាំងជាងច្បាប់ទៅទៀត ដូចជា ទំនាក់ទំនងរវាងបុគ្គលតាមខ្សែ តាមខ្នង ជាដើម ។ ទំនាក់ទំនងបែបនេះ ហៅថា បរិវារកិច្ច (Scott 1977) ។

ការប្រាស្រ័យទាក់ទង តាមការស្គាល់គ្នា តាមខ្សែ-ខ្នង ជាទង្វើសាមញ្ញមួយក្នុងគ្រប់សង្គម ។ ការប្រាស្រ័យទាក់ទងបែបនេះ បង្កើតបានជាគណនេយ្យភាពមួយ រវាងអ្នកដែលជាខ្នង (មេ) និងអ្នកដែលដើរតាម (កូនចៅ) ដែលមានរូបភាពដូចតទៅ៖ គណនេយ្យភាពនេះ គ្មានកំណត់តាមច្បាប់ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សរអ្វីទេ ប៉ុន្តែតាមការទុកចិត្ត និងការផ្ដល់ប្រយោជន៍ទៅវិញទៅមករវាងភាគីទាំងពីរ ។ ក្នុងន័យនេះ អ្នកតូច

ត្រូវមានគណនេយ្យភាពចំពោះអ្នកធំដែលជាខ្នងរបស់ខ្លួន ដោយត្រូវមានការស្មោះត្រង់ និងបម្រើ ឬផ្តល់ជាប្រយោជន៍អ្វីមួយដល់បុគ្គលនោះ ។ រីឯអ្នកធំវិញ ទោះគ្មាននិយាយ ឬចែងជាលាយលក្ខណ៍អក្សរអ្វី ក៏ត្រូវមានគណនេយ្យភាពចំពោះអ្នកតូចរបស់ខ្លួន ដោយត្រូវផ្តល់ការការពារ និងប្រយោជន៍មួយចំនួន ដែលភាគីទាំងសងខាងរំពឹងទុក ។ ដោយគ្មានអ្វីចែងជាលាយលក្ខណ៍អក្សរ ការរំពឹង និងទំនាក់ទំនង រវាងបុគ្គលនៅក្នុងបរិវារកិច្ចច្រើនអាស្រ័យទៅតាមទម្លាប់ពីមុនមក ឬតាមកត្តាវប្បធម៌ និងប្រពៃណីដែលមានស្រាប់ ។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បរិវារកិច្ចជ្រៀតចូលយ៉ាងជ្រៅ និងដំណើរការប្រកបដោយឥទ្ធិពលនៅក្នុងការងារគ្រប់គ្រងរដ្ឋបាលសាធារណៈ ។ ដូច្នេះ គណនេយ្យភាពតាមផ្លូវច្បាប់ (ដូចបានពិភាក្សាខាងលើ) តែងតែជំពាក់វ៉ាក់វិនជាមួយនឹងគណនេយ្យភាពតាមបែបបរិវារកិច្ច ។ បរិវារកិច្ចក្នុងន័យនេះអាចកើតមានរវាងមនុស្សតែពីរបីនាក់ ឬរវាងមនុស្សច្រើនរួមគ្នាជាប្រព័ន្ធមួយ ។ ក្នុងនោះ បុគ្គលម្នាក់អាចជាខ្នងរបស់មនុស្សរាប់សិបនាក់ដែលនៅក្រោមខ្លួន តែគាត់ក៏អាចជាអ្នកដើរតាម និងបម្រើសេវាដល់បុគ្គលម្នាក់ទៀតដែលមានឥទ្ធិពល និងជាខ្នងរបស់គាត់ដែរ ។ ទំនាក់ទំនងនេះប្រទាក់ក្រឡាគ្នាបង្កើតជាប្រព័ន្ធមើលមិនឃើញមួយ មានទម្រង់ដូចជាពីរ៉ាមីត ភ្ជាប់បន្តគ្នាតាំងពីអ្នកដែលមានអំណាចខ្លាំងបំផុត មកដល់អ្នកដែលតូចតាចនៅខាងក្រោម ។

នៅប្រទេសអាហ្វ្រិកមួយចំនួន បរិវារកិច្ចបានជ្រៀតចូលយ៉ាងខ្លាំងទៅក្នុងប្រព័ន្ធរដ្ឋបាលសាធារណៈ ដែលអនុញ្ញាតឱ្យមន្ត្រីគ្រប់ជាន់ថ្នាក់ អាចប្រើអំណាច និងខ្សែបណ្តាញ ដើម្បីប្រយោជន៍របស់ខ្លួន ដោយមិនគិតដល់ច្បាប់ និងផលប្រយោជន៍របស់សង្គមទេ ។ ប្រព័ន្ធបែបនេះ មិនមានបែងចែកច្បាស់រវាងអ្វីជាការងាររដ្ឋ និងអ្វីជាការងារ ឬប្រយោជន៍របស់បុគ្គលទេ ។ អ្នកស្រាវជ្រាវដែលសិក្សាពី ប្រព័ន្ធរដ្ឋបាលក្នុងប្រទេសអាហ្វ្រិកទាំងនេះ បានសន្និដ្ឋានថា បរិវារកិច្ច គឺជាមូលហេតុចំបងនាំឱ្យមានអំពើពុករលួយ និងកង្វះការអភិវឌ្ឍ (Bratton and van de Walle 1994) ។

អំពើពុករលួយជាបញ្ហាធំមួយ ដែលរាជរដ្ឋាភិបាលកំពុងព្យាយាមលុបបំបាត់ ហើយដែលទ្រឹស្តីបរិវារកិច្ចខាងលើ អាចជួយបំភ្លឺអំពីមូលហេតុ ។ ចំណុចសំខាន់ គឺ គួរពិនិត្យឲ្យហួសពីអ្វីដែលមានចែងនៅក្នុងច្បាប់ ហើយផ្តោតទៅលើខ្សែបណ្តាញរវាងបុគ្គលនៅក្នុងបរិវារកិច្ច និងវិធីដែលពួកគេប្រើអំណាច និងខ្សែបណ្តាញនោះ ដើម្បីទាញយក និងបែងចែកប្រយោជន៍នៅក្នុងក្រុមរបស់គេ ។ គួររំលឹកដែរថា ការអនុវត្តបែបនេះមិនមែនមានតែនៅកម្ពុជា ឬនៅប្រទេសអាហ្វ្រិកនោះទេ តែមាននៅគ្រប់សង្គម រួមទាំងប្រទេសរីកចម្រើនផង ។ ចំណុចខុសគ្នានៅត្រង់ថា ប្រទេសកំពុងអភិវឌ្ឍន៍ មានបរិវារកិច្ចច្រើនរាលដាលស្ទើរគ្រប់វិស័យ តាំងពីលើដល់ក្រោម ហើយពេលខ្លះមានការប្រើឥទ្ធិពលបរិវារកិច្ចយ៉ាងចំហ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។

តើទ្រឹស្តីនេះ អាចជួយបានកម្រិតណាក្នុងការស្វែងយល់ពីបញ្ហាគណនេយ្យភាពនៅកម្ពុជា? ជាចំណុចវិជ្ជមាន វាអាចជួយពន្យល់ពីលក្ខណៈជាប្រព័ន្ធ ឬជាបណ្តាញ នៃអំពើពុករលួយដែលកើតមានឡើង ។ ប៉ុន្តែប៉ុណ្ណេះ មិនទាន់គ្រប់គ្រាន់ឡើយ ពីព្រោះដើម្បីធ្វើកំណែទម្រង់ និងពង្រឹងគណនេយ្យភាព ត្រូវមានការយល់ដឹងលើសពីការចង្អុលថា បុគ្គលនេះ ឬក្រុមនោះជាជនពុករលួយ គ្មានគណនេយ្យភាពចំពោះច្បាប់ និងចំពោះប្រជាជន ។ ជាចំណុចអវិជ្ជមាន ទ្រឹស្តីនេះមើលឃើញរាល់រូបភាពនៃបរិវារកិច្ចថា សុទ្ធតែអវិជ្ជមាន និងរាំងស្ទះដល់ការអភិវឌ្ឍ (Picher *et. al.* 2009) ។ ការយល់ឃើញបែបនេះ ក៏ត្រឹមត្រូវដែរ ជាពិសេសបើពិនិត្យលើករណីរបស់ប្រទេសអាហ្វ្រិកក្រីក្រមួយចំនួនធំ ។ ប៉ុន្តែអ្នកសិក្សាលើការអភិវឌ្ឍនៅប្រទេសអាស៊ីមួយចំនួន ដូចជា កូរ៉េខាងត្បូង តៃវ៉ាន់ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងថៃ បានកត់សម្គាល់ថា ប្រទេសទាំងនេះ សុទ្ធតែធ្លាប់មានបរិវារកិច្ច និងអំពើពុករលួយយ៉ាងច្រើន ប៉ុន្តែ នៅតែអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនបាន (Khan and Jomo 2000) ។ ដូច្នេះ ទោះបី មានគណនេយ្យភាពបែបបរិវារកិច្ចយ៉ាងក្រាស់ក្រែលក៏ដោយ ក៏ក្នុងរយៈពេលវែង រដ្ឋាភិបាលក្នុងប្រទេសទាំងនេះនៅតែមានគណនេយ្យភាពចំពោះប្រជាជន ជាពិសេសលើការធានាឱ្យប្រជាជនមានជីវភាពល្អប្រសើរឡើង ។

ចំណុចសំខាន់មួយដែលបានរកឃើញ គឺមេដឹកនាំនៅក្នុងប្រទេសអាស៊ីជឿនលឿនដូចរៀបរាប់ខាងលើ ទោះមិនអាចបំបាត់អំពើពុករលួយបានទាំងស្រុង ក៏មានទេព្យកោសល្យល្អក្នុងការបង្វែរបរិវារកិច្ចទាំងនេះ ឱ្យមានប្រយោជន៍ខ្លះដល់ប្រព័ន្ធសេដ្ឋកិច្ចជាតិក្នុងរយៈពេលវែង ។ ឧទាហរណ៍ ទោះបីមានមន្ត្រីជាច្រើន បានប្រព្រឹត្តអំពើពុករលួយ និងមិនគោរពតាមគណនេយ្យភាពតាមផ្លូវច្បាប់ក្តី រដ្ឋាភិបាលនៅតែសម្រេចបានស្ថិរភាពនយោបាយ និងបរិយាកាសវិនិយោគល្អ ដែលជម្រុញឱ្យមន្ត្រីទាំងនោះ អាចប្រើធនធានរបស់ខ្លួនមកធ្វើវិនិយោគជាប្រយោជន៍ដល់សេដ្ឋកិច្ចក្នុងស្រុក ។ ករណីនេះ ខុសពីប្រទេសអាហ្វ្រិកមួយចំនួនធំ ដែលមន្ត្រីភាគច្រើនយកធនធានដែលខ្លួនរកបាន ទៅទុកក្នុងធនាគារនៅបរទេស ជាជាងធ្វើវិនិយោគក្នុងសេដ្ឋកិច្ចប្រទេសខ្លួន (Khan and Jomo 2000) ។

ភាពខុសគ្នារវាងករណីប្រទេសអាស៊ី និងអាហ្វ្រិក ជាឧទាហរណ៍បញ្ជាក់ច្បាស់ថា មិនមែនរាល់បរិវារកិច្ចសុទ្ធតែរាំងខ្ទប់ដល់ការអភិវឌ្ឍប្រទេសនោះទេ តែវាអាស្រ័យទៅតាមប្រភេទ និងស្ថានភាពនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗ ។ មួយវិញទៀត គេក៏មិនអាចរំពឹងឱ្យអភិបាលកិច្ច និងគណនេយ្យភាពក្នុងរដ្ឋមួយ ផ្លាស់ប្តូរពីទន់ខ្សោយ ទៅជារឹងមាំភ្លាមៗនោះដែរ គឺអ្វីៗត្រូវប្រព្រឹត្តទៅដោយសន្សឹមៗ ។ ដូច្នេះ អ្នកស្រាវជ្រាវត្រូវវិភាគលើលក្ខណៈនៃការវិវត្តសន្សឹមៗនេះ មុននឹងធ្វើការសន្និដ្ឋានអំពីលម្អាននៃការពង្រឹងគណនេយ្យភាពនៅក្នុងរដ្ឋមួយ (van de Walle 2007) ។

ការស្វែងយល់ពី គណនេយ្យភាពរដ្ឋបាលសាធារណៈនៅកម្ពុជា កាន់តែត្រូវមានការប្រយ័ត្នប្រយែងថែមទៀត ដោយសារប្រទេសនេះធ្លាប់ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃ និងរបបប្រល័យពូជសាសន៍ដែលបានប៉ះពាល់យ៉ាងខ្លាំង មិនត្រឹមតែលើសមត្ថភាពរបស់រដ្ឋប៉ុណ្ណោះទេ ប៉ុន្តែទៅលើផ្នត់គំនិត និងទំនាក់ទំនង របស់

ប្រជាជនជាមួយរដ្ឋថែមទៀត ។ ឧទាហរណ៍ នៅពេលប្រជាជននៅប្រទេសជឿនលឿន សំដែងភាពក្លាហានទាមទារឱ្យរដ្ឋត្រូវតែមានគណនេយ្យភាពចំពោះខ្លួន ប្រជាជនកម្ពុជាបែរជាមានការខ្លាចរអារ ចង់តែជៀសឱ្យឆ្ងាយពីពាក្យថា រដ្ឋអំណាច ដោយហេតុថា ពួកគាត់ធ្លាប់ឆ្លងកាត់ព្រឹត្តិការណ៍ដ៏រន្ធត់ ដែលរដ្ឋធ្លាប់បានប្រព្រឹត្តមកលើខ្សែជីវិតរបស់គាត់ និងក្រុមគ្រួសារគាត់ ដូចជាក្នុងរបបខ្មែរក្រហម ជាដើម (Chandler 2008) ។

ចំណុចខាងលើបង្ហាញកាន់តែច្បាស់ថា ដើម្បីស្វែងយល់ពីគណនេយ្យភាពនៅកម្ពុជា គេមិនអាចបំភ្លេចចោលនូវកត្តាប្រវត្តិសាស្ត្រ និងសង្គមរបស់ប្រទេសនេះ ហើយទាញយកទ្រឹស្ដីតាមលោកខាងលិចមកប្រើដោយត្រង់ៗបានឡើយ ។ ចំណែកឯទ្រឹស្ដីបរិវារកិច្ចដូចបានរៀបរាប់ខាងលើ ក៏នៅមិនគ្រប់គ្រាន់ដែរ ម្យ៉ាងដោយសារទ្រឹស្ដីនេះ មានទំនោរអគតិខ្លាំងពេក និងម្យ៉ាងទៀត ដោយសារវាមិនឱ្យតម្លៃគ្រប់គ្រាន់ដល់អ្វីដែលហៅថាបរិបទជាក់ស្ដែងរបស់ប្រទេសនីមួយៗ ។ ការសិក្សាស្រាវជ្រាវគួរបន្តស្វែងយល់ថែមទៀត អំពីសារជាតិនៃពាក្យថា គណនេយ្យភាពនៅកម្ពុជា និងអំពីលម្អាននៃការវិវត្តរបស់វា ដោយសង្ឃឹមថាអាចហុចលទ្ធផលជាការបង្កើតបានទ្រឹស្ដីសំយោគមួយ ដែលស៊ីជាមួយនឹងបរិបទនៅកម្ពុជា ។

## សេចក្ដីសង្ខេប និងគំនិតសម្រាប់ការសិក្សាស្រាវជ្រាវនាពេលអនាគត

អត្ថបទនេះបង្ហាញថា នៅពេលពិភាក្សាអំពីគណនេយ្យភាព មានផុសសំណួរមួយចំនួនដែលត្រូវបកស្រាយ ។ ទីមួយ តើគណនេយ្យភាពប្រភេទអ្វីដែលគេកំពុងពិភាក្សា? សំណួរនេះសំដៅដល់គណនេយ្យភាពនយោបាយ រដ្ឋបាល ហិរញ្ញវត្ថុ ច្បាប់ ។ល។ ក្នុងនោះ តើអ្នកណាត្រូវមានគណនេយ្យភាពចំពោះអ្នកណា? លើដែនសមត្ថកិច្ចអ្វី? និងយោងតាមច្បាប់ និងវិធានអ្វី? ទីពីរ ត្រូវស្វែងយល់ឱ្យច្បាស់អំពីប្រព័ន្ធដែលយកមកប្រើ ដើម្បីធានាឱ្យមានគណនេយ្យភាពប្រភេទណាមួយនោះ ។ ត្រង់នេះ គេអាចយកមកប្រើនូវទ្រឹស្ដីមួយចំនួនដូចបានរៀបរាប់ខាងលើ ដើម្បីជួយដល់ការវិភាគ ។ ចំណុចមួយដែលគួរចងចាំគឺ គណនេយ្យភាពពុំមែនកំណត់តែតាមអ្វីដែលមានចែងជាច្បាប់ និងជាលាយលក្ខណ៍អក្សរនោះទេ ។ កត្តាផ្សេងទៀត ដូចជាបរិវារកិច្ច ជាដើម ក៏ជះឥទ្ធិពលខ្លាំងទៅលើគណនេយ្យភាពដែរ ។ ដូច្នេះ គេត្រូវមើលទាំងលើកត្តាផ្លូវការ និងកត្តាមិនផ្លូវការ និងទំនាក់ទំនងរបស់វាទាំងពីរ ។

ទាក់ទងនឹងការសិក្សាស្រាវជ្រាវបន្ដអំពីគណនេយ្យភាព អត្ថបទនេះបង្ហាញថា នាបច្ចុប្បន្ន ការវិភាគភាគច្រើនពឹងផ្អែកលើទ្រឹស្ដីប្រទេសលោកខាងលិច ប៉ុន្តែខ្វះការឆ្លុះបញ្ចាំងមកក្នុងបរិបទជាក់ស្ដែងនៅកម្ពុជា ។ ភាគច្រើននៅពេលនិយាយពីបរិវារកិច្ចនៅកម្ពុជា គេច្រើនចាត់វាថា ជាទង្វើដែលនាំឱ្យមានអំពើពុករលួយ ។ ដូចបានលើកឡើងខាងលើ បរិវារកិច្ចពុំមែនសុទ្ធតែជាអំពើខុសឆ្គងទាំងអស់នោះទេ ។ វាអាចល្អ និងអាចមិនល្អ ។ ការសិក្សាថ្មីៗមួយចំនួនបង្ហាញថា ពេលខ្លះបរិវារកិច្ច ក៏អាចជួយដល់សង្គមដែរ ។ ដូច្នេះ សម្រាប់ប្រទេសកម្ពុជា៖

- ទីមួយ ក្នុងការសិក្សាស្រាវជ្រាវនាពេលអនាគត គួរស្វែងយល់បន្ថែមអំពីគណនេយ្យភាពតាមបរិវារកិច្ច និងផលវិជ្ជមាន និងអវិជ្ជមាន របស់វា ។ គួរមើលដែរថា តើគណនេយ្យភាពមានរូបភាពយ៉ាងណា នៅពេលដែលកំណែទម្រង់រដ្ឋ អនុវត្តលាយឡំគ្នាជាមួយបរិវារកិច្ច នៅក្នុងបរិបទជាក់លាក់ណាមួយ ដូចជានៅក្នុងការងារវិមជ្ឈការ ការផ្ដល់សេវាសាធារណៈ ការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពសហគមន៍ ។ល។
- ទីពីរ ការសិក្សាអំពីគណនេយ្យភាពនៅកម្ពុជា គួរបន្តដកបទពិសោធន៍ពី ប្រទេសទើបងើបពីសង្គ្រាមផ្សេងទៀត ប៉ុន្តែក្នុងពេលជាមួយគ្នា គួរធ្វើការប្រៀបធៀប និងដកបទពិសោធន៍ឱ្យបានច្រើនថែមទៀត ពីប្រទេសនៅអាស៊ីអាគ្នេយ៍ ជាអាទិ៍ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ ឬ វៀតណាម ដែលជាប្រទេសមានវប្បធម៌ ប្រពៃណី និងកត្តាសង្គមមួយចំនួនស្រដៀងគ្នានឹងកម្ពុជា ។ នៅប្រទេសអាស៊ីអាគ្នេយ៍ទាំងនេះ គេបានកត់សំគាល់ថា មានការអនុវត្តបរិវារកិច្ច ការប្រើខ្សែខ្នងយ៉ាងក្រាស់ក្រែល ប៉ុន្តែនៅតែអាចធ្វើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនបានយ៉ាងប្រសើរ (Khan and Jomo 2000) ។

ពិតណាស់ បណ្ដាប្រទេសដូចរៀបរាប់ខាងលើ គេមានវាសនាល្អជាងកម្ពុជា ព្រោះគ្មានសង្គ្រាមរ៉ាំរ៉ៃ គ្មានរបបប្រល័យពូជសាសន៍ និងមានការអភិវឌ្ឍក្នុងកម្រិតមួយ ដែលដាច់ឆ្ងាយពីកម្ពុជា ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី សម្រាប់ការសិក្សាស្រាវជ្រាវ គេនៅតែអាចទទួលបានមេរៀនជាច្រើនទាក់ទងនឹងគណនេយ្យភាព ការធ្វើកំណែទម្រង់ និងបរិវារកិច្ច ជាពិសេសប្រសិនបើផ្ដោតការយកចិត្តទុកដាក់ ទៅលើអំឡុងពេលដែលប្រទេសទាំងនេះ ទើបមានស្ថិរភាពនយោបាយ និងសន្ទុះសេដ្ឋកិច្ចក្នុងពេល ២ ឬ ៣ទសវត្សរ៍ កន្លងទៅនេះ ។

## ឯកសារយោង

Bratton, M. & N. van de Walle (1994), "Neo-patrimonial regimes and political transition in Africa", *World Politics* 46 (4), pp. 453–489

Chandler, D. (2008). A history of Cambodia. Westview Press, Colorado

Cheema, G.S. & D.A. Rondinelli (eds.) (2007), *Decentralizing governance: Emerging concepts and practices* (Harrisonburg, VA: R.R. Donnelley)

Grindle, M. (2004), "Good enough governance: poverty reduction and reform in developing countries", Governance 17 (4), pp. 525–548

Khan, M. & K. Jomo (2000), Rent, rent seeking and economic development: theory and evidence in Asia (Cambridge: Cambridge University Press)

Lindberg, S.I. (2009), *Accountability: the core concept and its subtypes* (London: ODI)

McLoughlin, C. (2010), *Topic guide on fragile states,* (Birmingham: International Development Department)

Minogue, M. (2001), "The internationalization of new public management", in W. McCourt & M. Minogue (eds.), *The internationalization of public management* (Cheltenham, UK: Edward Elgar) pp. 1–19

Mulgan, R.D. (2000), "Accountability: An ever-expanding concept?", *Public Administration,* 78 (3), pp. 555–573

North, D.C. (1990), *Institutional change and economic performance* (Cambridge: Cambridge University Press)

Pak, K., V. Horng, N. Eng, S. Ann, S. Kim, J. Knowles and D. Craig (2007), *Accountability and noe-patrimonialism in cambodia: A critical literature review.* CDRI, Phnom Penh, Cambodia

Pitcher, A., Moran, M. and Johnston, M (2009), Rethinking Patrimonialism and Neopatrimonialism in Africa, *African Studies Review,* 52(1), 125-156

Scott, C. (1977), "Patron-client politics and political change." *Southeast Asia* (66): 91-113.

Thon, V, S. Heng, Kruy, V and Tem, L (2011). *Assessment of One Window Service Offices and District Ombudsmen Pilot Projects.* CDRI, Phnom Penh, Cambodia

van de Walle, N (2007), The path from neo-patrimonialism: democracy and clientelism in Africa today. *Center for International Studies* 3(07)

Weber, M (1978), *Economy and society.* Berkeley: University of California Press.

World Bank (1997), *The state in a changing world.* World Development Report 1997, Oxford University Press. Washington DC

World Bank (2004), *Making services work for poor people.* World Development Report, The World Bank, Washington DC

World Bank (2005), *Social accountability in the public sector: A conceptual and learning module,* The World Bank, Washington DC

---

*តពីទំព័រ ៦* **ព្រៃឈើ និង...**

ទទួលចំណូលពីព្រៃឈើបានប្រមាណ ២៤% នៃប្រាក់ចំណូលសរុបដែរ ប៉ុន្តែបើគិតជាសាច់ប្រាក់ គ្រួសារក្នុងក្រុមនេះ ទទួលអត្ថប្រយោជន៍ពីព្រៃឈើ បានច្រើនជាងក្រុមឯទៀតៗ ។

### ឯកសារយោង

Bruce, M. K., Yim, C., Prom, T., & Tom, E. (2004), Focusing on Cambodia's High Value Forests: Livelihood and Management (Phnom Penh: CDRI & Wildlife Conservation Society)

CFI (2006), Proceedings of non-timber forest products (NTFP) workshop and seminar held on 7-8 December 2006 in Phnom Penh

Chao L. (2009), Agricultural Mechanisation and Agricultural Development Strategies in Cambodia, country report for the fifth session of the technical committee of UNAPCAM held on 14-15 October 2009 in Los Banos, the Philippines

Chhatre, A. & Arun, A. (undated), Carbon Storage and Livelihoods Generation through Improved Governance of Forest Commons, IFRI Working Paper No. W09I.01 http://sitemaker.umich.edu/ifri/files/carbon_and_livelihoods_ver7.pdf (accessed 14 January 2011)

FAO (2010), Forest and Climate Change Working Paper No.7: Forest and Climate Change in the Asia-Pacific Region (Rome: FAO)

Hansen K. & Neth T. (2006), Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia,, CDRI Working paper No. 33 (Phnom Penh: CDRI)

Poverty and Environment Network (2007), Prototype Questionnaire Version 4 in English, , http://www.cifor.cgiar.org/pen (accessed 1 July 2008)

Poverty and Environment Network (2009) PEN Narrative (unpublished)

RGC (2010), National Strategic Development Plan, Update 2009-2013

Tola, Prom (2009), Beyond Subsistence: Trade Chain Analysis of Resin Products in Cambodia (Phnom Penh: NTFP Exchange Programme for South and Southeast Asia)

# ការប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (PSM) ដើម្បីបង្កើតគំរូតាងប្រៀបធៀបក្នុងការវាយតម្លៃគម្រោង៖ ករណីសិក្សានៃគម្រោងដឹកជញ្ជូន[១]

## សេចក្តីផ្តើម

ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ការគាំទ្រដល់មហាអនុតំបន់មេគង្គ (GMS) តាំងតែពីពេលបង្កើតឡើងក្នុងឆ្នាំ១៩៩២ ដោយប្រទេសកម្ពុជា ចិន ឡាវ ភូមា ថៃ និងវៀតណាម ក្នុងបំណងពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចទៅវិញទៅមក ។ នៅឆ្នាំ២០០២ ប្រទេស GMS ខាងលើ បានអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្រ GMS ២០០២-១២ ដែលមានចែងពីរបៀបវារៈអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយមួយ និងបានគូសបញ្ជាក់ពី តម្រូវការធ្វើសហប្រតិបត្តិការបង្កើតគោលនយោបាយ និងកម្មវិធីនានា ជាបន្ថែមលើទំនាក់ទំនងខាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកស្ទួយកំណើនប្រកបដោយសមធម៌ និងមិនខូចខាតដល់បរិស្ថាន ។

ការស្តារជួសជុល និងកែលំអប្រព័ន្ធដឹកជញ្ជូនក្នុងប្រទេស GMS គឺជាវិស័យមួយ ក្នុងចំណោមវិស័យសហប្រតិបត្តិការជាអាទិភាពទាំង ៩ ដែលបានកំណត់ឡើង[២] ។ គម្រោងច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃ GMS (GMS-SCC) បានជួយស្តារឡើងវិញនូវផ្លូវជាតិលេខ៣៣ នៅកម្ពុជា និងផ្លូវមួយកំណាត់ទៀតនៅវៀតណាមខាងត្បូង ។ គម្រោងនេះរំពឹងថា នឹងជះឥទ្ធិពលយ៉ាងច្រើន ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការទទួលបានឱកាសការងារ ទីផ្សារ និងសេវាសង្គមកាន់តែប្រសើរ ។

គម្រោង GMS-SCC បានដំណើរការគួរឲ្យកត់សម្គាល់ ។ ប៉ុន្តែការវាយតម្លៃពាក់កណ្តាលអាណត្តិ លើក្របខ័ណ្ឌយុទ្ធសាស្ត្របង្ហាញថា ទំហំ និងវិសាលភាពជាក់លាក់ ដែលគម្រោងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងកែលំអសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងទៀត មិនអាចវាស់បានទេ ប្រសិនបើមិនមានព័ត៌មានមូលដ្ឋានសព្វគ្រប់លើគម្រោង សម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃលើជំនួយ ។ ការប៉ាន់ស្មានបែបសាមញ្ញមួយអំពីផលប៉ះពាល់នៃអន្តរាគមន៍ គឺ ការប្រៀបធៀបពីលទ្ធផលទាក់ទង រវាងក្រុមរងប្រព្រឹត្តិកម្ម (ប្រជាជនក្នុងតំបន់អនុវត្តគម្រោង) ជាមួយនឹងក្រុមមិនរងប្រព្រឹត្តិកម្ម (ប្រជាជនក្នុងតំបន់មិនអនុវត្តគម្រោង និងជាក្រុមសម្រាប់ប្រៀបធៀប) ។ ប៉ុន្តែលទ្ធផលរកឃើញខុសប្លែកគ្នារវាងក្រុមទាំងពីរនេះ មិនអាចជឿជាក់បានទេ ប្រសិនបើមិនលុបបំបាត់ចោលភាពលំអៀងនានា (Ravallion 2001) ។ Propensity score matching (PSM) ជាបច្ចេកទេសស្ថិតិមួយ ដែលអាចឲ្យអ្នកស្រាវជ្រាវរកឃើញកត្តាលំអៀងក្នុងក្រុមទាំងពីរ ដើម្បីលុបបំបាត់វាចោល ។

ការសិក្សានេះ សំដៅវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃគម្រោង GMS-SCC នៅកម្ពុជា ដើម្បី (១) រៀបចំ និងបង្កើតទិន្នន័យគោលពេញលេញមួយ និងបកស្រាយលើសូចនាករពាក់ព័ន្ធមួយចំនួន (២) វាយតម្លៃ និងផ្តល់ទិន្នន័យមូលដ្ឋានសព្វគ្រប់ សម្រាប់វាយតម្លៃនៅតំបន់អនុវត្តគម្រោង និងតំបន់មិនអនុវត្តគម្រោង ដែលបានជ្រើសរើស (សម្រាប់ប្រៀបធៀប) និង (៣) ប្រើវិធីសាស្ត្រ PSM បង្កើតក្រុមរងប្រព្រឹត្តិកម្ម (treatment group) និងក្រុមមិនរងប្រព្រឹត្តិកម្ម (ទុកប្រើជាក្រុមសម្រាប់ប្រៀបធៀប) ។

## វិធីសាស្ត្រស្រាវជ្រាវ

អង្កេតគ្រួសារមួយបានធ្វើឡើង ដើម្បីកំណត់សូចនាករមូលដ្ឋាននានា ។ គ្រួសារគំរូតាងចែកចេញជា ២ក្រុម ទៅតាមទីតាំងភូមិសាស្ត្រ គឺ តំបន់ក្នុងគម្រោង (ក្រុមក្នុងគម្រោង) និងតំបន់ក្រៅគម្រោង (ក្រុមក្រៅគម្រោង) ។ តំបន់ក្នុងគម្រោង ត្រូវបានជ្រើសរើសក្នុងចំងាយ ៥គីឡូម៉ែត្រ សងខាងផ្លូវ ហើយតំបន់ក្រៅគម្រោង ត្រូវបានជ្រើសរើសឆ្ងាយជាង ៥គីឡូម៉ែត្រ ពីសងខាងផ្លូវ ។ គេជ្រើសរើសដោយចៃដន្យ ៤៥០គ្រួសារ សម្រាប់តំបន់ក្នុងគម្រោង និង ៣៦០គ្រួសារ សម្រាប់តំបន់ក្រៅគម្រោង ។ ក្រុមស្រាវជ្រាវ បានប្រើអង្កេតគ្រួសារដើម្បីធ្វើវិភាគបែបពិពណ៌នាពីសូចនាករខាងដឹកជញ្ជូន និងខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ។ ដោយសារទិន្នន័យមូលដ្ឋាននេះ នឹងត្រូវប្រើប្រាស់សម្រាប់តាមដាន និងវាយតម្លៃគម្រោង ដូច្នេះក្រុមស្រាវជ្រាវបានប្រើវិធីសាស្ត្រ PSM ដើម្បីកំណត់ពីលក្ខណៈសំគាល់ស្រដៀងគ្នានៃគំរូតាងទាំងពីរក្រុម និងកាត់បន្ថយលំអៀងបណ្តាលពីកំហុសក្នុងការជ្រើសរើសគំរូតាង ។ គ្រួសារដែលមិនស៊ីគ្នានឹងចរិតលក្ខណៈបានកំណត់ ត្រូវគេកាត់ចេញពីគំរូតាង ដើម្បីធ្វើឲ្យអថេរសម្រាប់វាស់វែងក្រុមទាំងពីរមានតុល្យភាព[៣] ។

---

១ អត្ថបទនេះរៀបរៀងដោយ លោក ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី លោក គីម សុធន ជាអ្នកស្រាវជ្រាវ ហើយនិងលោក ឈឹម ឈន់ និងលោកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវនៅ CDRI ។ អត្ថបទនេះជាសេចក្តីសង្ខេបលទ្ធផលពិសោធន៍នៃគម្រោងមួយរបស់ CDRI គឺ ការវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ ដែលធ្វើឡើងក្នុងឆ្នាំ២០០៩-១០ ក្រោមជំនួយហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ។

២ វិស័យអាទិភាពទាំង៩ គឺ វិស័យដឹកជញ្ជូន ទូរគមនាគមន៍ ថាមពល បរិស្ថាន ទេសចរណ៍ ការសម្របសម្រួលពាណិជ្ជកម្ម ការវិនិយោគ ការអភិវឌ្ឍន៍ធនធានមនុស្ស និងកសិកម្ម ។

៣ ព័ត៌មានលំអិត ស្តីពីវិធីសាស្ត្រស្រាវជ្រាវ មានចុះក្នុងឯកសាររបស់ Theng and Kem (ជិតបោះពុម្ពផ្សាយ) និង Hing et al. (ជិតបោះពុម្ពផ្សាយ) ។

## លទ្ធផលសំខាន់ៗបានពីពិសោធន៍

### ស្ថិតិបែបពិពណ៌នា

តារាង១ សង្ខេបពីភាពខុសប្លែកគ្នារវាងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង តាមតម្លៃ t (t-value) របស់វា ។ t-value បង្ហាញថាមានភាពខុសប្លែកគ្នាច្រើនរវាងក្រុមទាំងពីរ ក្នុងលក្ខណៈសំគាល់ខាងប្រជាសាស្ត្រ និងសុខុមាលភាព ។ ភាពខុសប្លែកគ្នាខ្លាំងហាក់កើតមានចំពោះលក្ខណៈសំគាល់របស់មេគ្រួសារ ដែលមានភេទ អាយុ ស្ថានភាពមានប្តីប្រពន្ធ កម្រិតអប់រំ ចំនួនឆ្នាំរស់នៅក្នុងតំបន់ កម្រិតប្រាក់ចំណូល អាជីវកម្មខ្នាតតូច និងចំពោះលក្ខណៈសំគាល់របស់គ្រួសារ ដែលមាន សន្ទស្សន៍ទ្រព្យសម្បត្តិ តម្លៃផ្ទះ និងទ្រព្យជាប់លាប់ ប្រាក់ចំណូលក្នុងមនុស្សម្នាក់ ចំណាយលើការប្រើប្រាស់ក្នុងមនុស្សម្នាក់ ចំណាយធ្វើកសិកម្ម និងចំណេញដុល ។ មានតែសូចនាករខាងប្រជាសាស្ត្រ និងជីវភាពពីរ-បីប៉ុណ្ណោះ ដែលគ្មានការខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ។ លទ្ធផលទាំងនេះបង្ហាញថា មានភាពលំអៀងខ្លះក្នុងការជ្រើសរើសគំរូតាង ទោះបីគំរូតាងត្រូវបានជ្រើសរើសដោយចៃដន្យក្តី ។

### ក្រុមគ្រួសារក្រោយផ្ទឹមផ្ទង

ក្រុមស្រាវជ្រាវ បានប្រើវិធីសាស្ត្រ PSM ដើម្បីកាត់បន្ថយភាពលំអៀង និងបង្កើតលក្ខណៈសំគាល់ស្រដៀងគ្នានៃក្រុមក្នុងគម្រោង និងក្រៅគម្រោង សម្រាប់ការសិក្សាវាយតម្លៃពីផលប៉ះពាល់ទៅថ្ងៃអនាគត (Ravallion 2001, Caliendo & Kopeinig 2008, World Bank 2002) ។ តារាង២ បង្ហាញតួលេខប៉ាន់ស្មានបានពីការប្រើគំរូឡូហ្ស៊ីត (logit model) ដើម្បី

**តារាង១៖ ការពិពណ៌នា និងភាពខុសប្លែកគ្នានៃអថេរ (មធ្យមក្នុងគំរូតាង)**

| អថេរ | ក្នុងគម្រោង | ក្រៅគម្រោង | ភាពខុសប្លែក | T-value |
|---|---|---|---|---|
| *អថេរមិនឯករាជ្យ (គម្រោងធនាគារអភិវឌ្ឍន៍អាស៊ី)* | 1 | 0 | | |
| *អថេរសម្រាប់ប្រៀបធៀប* | | | | |
| ទំហំគ្រួសារ | 5.34 | 5.18 | 0.16 | 1.2 |
| ចំនួននារីអាយុ១៥-៤៥ឆ្នាំ | 1.36 | 1.33 | 0.03 | 0.4 |
| កម្លាំងពលកម្មគ្រួសារ | 4.15 | 3.96 | 0.19 | 1.6 |
| ចំនួនឆ្នាំរស់នៅក្នុងភូមិ | 4.53 | 3.39 | 1.14* | 1.8 |
| ភេទមេគ្រួសារ (លេខតំណាង 1=បុរស, 0=ស្ត្រី) | 0.76 | 0.84 | -0.08*** | -2.7 |
| អាយុមេគ្រួសារ | 50.80 | 46.69 | 4.12*** | 4.3 |
| អាយុមេគ្រួសារលើកជាការ៉េ | 2763.1 | 2358.2 | 404.9*** | 4.1 |
| ស្ថានភាពមានប្តីប្រពន្ធរបស់មេគ្រួសារ(១=រៀបការ , 0= ផ្សេងទៀត) | 0.76 | 0.82 | -0.06** | -2.0 |
| កម្រិតអប់រំរបស់មេគ្រួសារ(ចំនួនឆ្នាំ) | 3.64 | 4.20 | -0.56** | -2.5 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្ម | 100.96 | 67.50 | 33.46*** | 3.9 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្មលើកជាការ៉េ | 27460.4 | 15691.6 | 11768.8** | 2.2 |
| ភាពអត់ការងារធ្វើ(១=អត់ការងារ, 0=មានការងារ) | 0.29 | 0.35 | -0.05 | -1.6 |
| មេគ្រួសារជាមន្ត្រីរាជការ | 0.063 | 0.056 | 0.008 | 0.5 |
| មេគ្រួសារជាពលករកសិដ្ឋាន | 0.079 | 0.095 | -0.016 | -0.8 |
| អាជីវកម្មខ្នាតតូចរបស់មេគ្រួសារ | 0.33 | 0.26 | 0.07** | 2.3 |
| ចំនួនសកម្មភាពមិនមែនកសិកម្មរបស់មេគ្រួសារ | 0.85 | 0.81 | 0.04 | 0.9 |
| សន្ទស្សន៍ទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារ | 0.85 | -1.04 | 1.89*** | 14.8 |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុប | 377.5 | 440.4 | -62.9** | -2.0 |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុបលើកជាការ៉េ | 359788.1 | 343831.0 | 15957.1 | 0.2 |
| តម្លៃផ្ទះ | 1014.4 | 424.7 | 589.7*** | 4.4 |
| តម្លៃផ្ទះលើកជាការ៉េ | 7409425.0 | 395630.6 | 7013794.0 | 1.6 |
| *អថេរវាស់វែងលទ្ធផល ( ការប៉ះពាល់រំពឹងទុកនៃគម្រោងផ្លូវ)* | | | | |
| ប្រាក់ចំណូលប្រចាំថ្ងៃ/១នាក់(រៀល) | 3801.8 | 3218.9 | 582.9*** | 3.1 |
| ចំណាយលើអាហារប្រចាំថ្ងៃ/១នាក់(រៀល) | 2518.4 | 2372.0 | 146.4 | 1.6 |
| ចំណាយប្រើប្រាស់ប្រចាំថ្ងៃមិនមែនអាហារ/១នាក់(រៀល) | 1770.2 | 1503.2 | 267.0** | 2.0 |
| ចំណាយប្រើប្រាស់សរុបប្រចាំថ្ងៃ/១នាក់ | 4288.6 | 3875.2 | 413.3** | 2.2 |
| ចំណាយផលិតកម្មលើស្រូវ/១ហិកតា(ម៉ឺនរៀល) | 180.4 | 148.7 | 31.8*** | 2.7 |
| ចំណេញដុលលើស្រូវ/១ហិកតា(ម៉ឺនរៀល) | 52.9 | 71.1 | -18.2* | -1.7 |
| ចំណេញដុលមិនមែនស្រូវ/១ហិកតា(ម៉ឺនរៀល) | 90.84 | 153.5 | -62.7 | -1.4 |

Level of significance * at 10 percent; ** at 5 percent; *** at 1 percent.

*ប្រភព៖ អង្កេតគ្រួសារ ខែធ្នូ ២០០៩*

ផ្គូផ្គងគ្រួសារក្នុងតំបន់អនុវត្តគម្រោង GMS-SCC ជាមួយគ្រួសារក្រៅតំបន់គម្រោង ។ លទ្ធផលពីការផ្គូផ្គង បង្ហាញថា មានតែអថេរពីរ-បីប៉ុណ្ណោះ (កម្រិតអប់រំរបស់មេគ្រួសារ និងទ្រព្យសម្បត្តិ) ដែលមានសារៈសំខាន់ខាងស្ថិតិ ហើយរឿងនេះ បង្ហាញពីភាពស្រដៀងគ្នា រវាងគ្រួសារក្នុងតំបន់គម្រោង និងតំបន់ក្រៅគម្រោងដែលបានផ្គូផ្គង ។

ក្រោយផ្គូផ្គងរួច ក្រុមស្រាវជ្រាវអាចរកឃើញគ្រួសារដែលត្រូវរក្សាទុក (on-support) និងគ្រួសារត្រូវជម្រុះចោល (off-support) ។ មាន ៩៨គ្រួសារ ក្នុងតំបន់គម្រោង ដែលត្រូវចាត់ចូលក្នុងក្រុមគ្រួសារត្រូវជម្រុះចោល ហើយ ៣៨៤គ្រួសារក្នុងតំបន់គម្រោង មានលក្ខណៈស៊ីគ្នាល្អជាមួយ ៣៥៩គ្រួសារនៅតំបន់ក្រៅគម្រោង ។ លក្ខណៈសំគាល់នៃគ្រួសារនានាដែលមិនអាចរកគូផ្គូផ្គងសមស្របបាន (ភាគច្រើនជាគ្រួសាររស់នៅតាមភូមិក្បែរព្រំដែន និងទីប្រជុំជន) ពាក់ព័ន្ធនឹងលទ្ធភាពទទួលបានអគ្គិសនី ទឹកម៉ាស៊ីន ឬប្រភពថាមពលសម្រាប់ចំអិនអាហារ ដែលខ្ពស់ហួសលទ្ធភាពគ្រួសារនៅតំបន់ក្រៅគម្រោង ។

លទ្ធផលបានមកពីការផ្គូផ្គងគ្រួសារក្នុងតារាង៣ បង្ហាញថា ភាពខុសប្លែកគ្នារវាងសូចនាករលទ្ធផលរពឹងទុក បានថយចុះយ៉ាងច្រើន ហើយតុល្យភាពបានកើនឡើង ។ ក្រោយការផ្គូផ្គងលក្ខណៈសំគាល់នានា រួមមាន ប្រាក់ចំណូលក្នុងមនុស្សម្នាក់ ចំណាយប្រើប្រាស់មិនមែនអាហារក្នុងមនុស្សម្នាក់ ចំណាយប្រើប្រាស់សរុប ចំណាយលើផលិតកម្មស្រូវ និងចំណូលដុលពីស្រូវ បង្ហាញថា មិនមានគំលាតគួរកត់សំគាល់ខាងស្ថិតិខ្លាំងទេ ហើយចំណាយប្រើប្រាស់ជាអាហារក្នុងមនុស្សម្នាក់ និងចំណេញដុលមិនមែនបានពីស្រូវ មានតុល្យភាពកាន់តែប្រសើរឡើង ។

ការផ្គូផ្គងនេះ ត្រូវតែផ្ទៀងផ្ទាត់បញ្ជាក់ ព្រោះយើងមិនបានដាក់លក្ខខណ្ឌលើគ្រប់អថេរទេ គឺ គ្រាន់តែបានប្រើ propensity score ដើម្បីពិនិត្យមើលថា តើនីតិវិធីផ្គូផ្គងនេះអាចបង្កើតតុល្យភាពសម្រាប់របាយអថេរពាក់ព័ន្ធនានា រវាងក្រុមក្នុងតំបន់គម្រោង និងក្រុមក្នុងតំបន់ក្រៅគម្រោង ឬទេ ។ លំអៀងស្តង់ដារ Pseudo-R2 និង t-statistics នៅមុននិងក្រោយការផ្គូផ្គង អាចប្រើជាសូចនាករដ៏សំខាន់សម្រាប់ត្រួតពិនិត្យគុណភាពនៃការផ្គូផ្គង (Caliendo & Kopeinig 2008) ។ មេដ្យាន និងមធ្យមនៃលំអៀងស្តង់ដារ បានធ្លាក់ចុះច្រើន មកត្រឹម ២,៧% និង ៣,៨% រៀងគ្នា បន្ទាប់ពីការផ្គូផ្គង ។ Caliendo and Kopeining (2008) លើកឡើងថា មេដ្យាន និងមធ្យម នៃលំអៀងស្តង់ដារ

តារាង២៖ Propensity score សម្រាប់ការផ្គូផ្គងគ្រួសារ (ការប៉ាន់ស្មានដោយប្រើគំរូ logit)

| អថេរសម្រាប់ប្រៀបធៀប | មេគុណ | លំអៀងស្តង់ដារ | z |
|---|---|---|---|
| ទំហំគ្រួសារ | -0.0125 | 0.1243 | -0.10 |
| ចំនួននារីអាយុ ១៥-៤៥ឆ្នាំ | 0.0189 | 0.1294 | 0.15 |
| កម្លាំងពលកម្មគ្រួសារ | -0.0496 | 0.1725 | -0.29 |
| ចំនួនឆ្នាំរស់នៅក្នុងភូមិ | 0.0107 | 0.0129 | 0.82 |
| ភេទមេគ្រួសារ(១=ប្រុស 0=ស្រី) | -0.3322 | 0.3406 | -0.98 |
| អាយុមេគ្រួសារ | 0.1027 | 0.0547 | 1.88 |
| អាយុមេគ្រួសារលើកជាការ៉េ | -0.0007 | 0.0005 | -1.35 |
| ស្ថានភាពមានប្តីប្រពន្ធនៃមេគ្រួសារ(១=រៀបការ 0=ផ្សេងទៀត) | 0.5167 | 0.3415 | 1.51 |
| កម្រិតអប់រំរបស់មេគ្រួសារ(ចំនួនឆ្នាំ) | -0.0857 | 0.0332 | -2.58** |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្ម | 0.0024 | 0.0021 | 1.11 |
| ប្រាក់ចំណូលរបស់មេគ្រួសារបានពីសកម្មភាពមិនមែនកសិកម្មលើកជាការ៉េ | 0.0000 | 0.0000 | -1.42 |
| ភាពអត់ការងារធ្វើ (១= អត់ការងារ 0= មានការងារ) | 0.0122 | 0.3557 | 0.03 |
| មេគ្រួសារជាមន្ត្រីរាជការ | -0.5475 | 0.4511 | -1.21 |
| មេគ្រួសារជាពលករកសិដ្ឋាន | -0.1324 | 0.3437 | -0.39 |
| អាជីវកម្មខ្នាតតូចរបស់មេគ្រួសារ | -0.0465 | 0.2379 | -0.20 |
| ចំនួនសកម្មភាពមិនមែនកសិកម្មរបស់មេគ្រួសារ | 0.2633 | 0.2506 | 1.05 |
| សន្ទស្សន៍ទ្រព្យសម្បត្តិទាំងអស់របស់គ្រួសារ | 0.8939 | 0.0880 | 10.15*** |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុប | -0.0024 | 0.0006 | -3.96*** |
| តម្លៃទ្រព្យសម្បត្តិគ្រួសារសរុបលើកជាការ៉េ | 0.0000 | 0.0000 | 2.04** |
| តម្លៃផ្ទះ | 0.0003 | 0.0003 | 0.85 |
| តម្លៃផ្ទះលើកជាការ៉េ | 0.0000 | 0.0000 | 0.35 |
| អញ្ញត្តិថេរ(Constant) | -2.0159 | 1.3431 | -1.50 |
| ចំនួនសង្កេតឃើញ | 801 | - | - |
| Pseudo-$R^2$ | 0.29 | - | - |

*Level of significance * at 10 percent; ** at 5 percent; *** at 1 percent.*

តារាង៣៖ ការប្រៀបធៀបអថេរវាស់វែងលទ្ធផល ក្រោយផ្គូផ្គងរួច (គិតតាមថ្លៃថេរប្រាក់រៀល ខែធ្នូ ២០០៩)

| អថេរវាស់វែងលទ្ធផល | ភាពខុសប្លែកគ្នា(ផ្គូផ្គងមិនស៊ីគ្នា) | | ភាពខុសប្លែកគ្នា (ផ្គូផ្គងស៊ីគ្នា) | |
|---|---|---|---|---|
| | ផ្គូផ្គងមិនស៊ីគ្នា | T-stat | ផ្គូផ្គងស៊ីគ្នា | T-stat |
| ប្រាក់ចំណូលគិតក្នុងមនុស្សម្នាក់ | 582.87 | 3.08 * * * | -86.53 | -0.40 |
| ចំណាយប្រើប្រាស់ជាអាហារក្នុងមនុស្សម្នាក់ | 146.37 | 1.65 | 64.52 | 0.63 |
| ចំណាយប្រើប្រាស់មិនមែនអាហារក្នុងមនុស្សម្នាក់ | 266.98 | 1.95 * * | 43.22 | 0.25 |
| ចំណាយប្រើប្រាស់សរុបក្នុងមនុស្សម្នាក់ | 413.34 | 2.2 * * | 107.74 | 0.48 |
| ចំណាយលើផលិតកម្មស្រូវ/ហិកតា(ម៉ឺនរៀល) | 31.77 | 2.74 * * * | 15.94 | 1.22 |
| ចំណេញដុលពីស្រូវ/ហិកតា(ម៉ឺនរៀល) | -18.24 | -1.75 * | -7.10 | -0.51 |
| ចំណេញដុលមិនមែនបានពីស្រូវ/ហិកតា(ម៉ឺនរៀល) | -62.67 | -1.35 | -39.01 | -0.73 |

*Level of significance * at 10 percent; * * at 5 percent; * * * at 1 percent.*

ក្រោម ៣% និង ៥% ក្រោយការផ្គូផ្គង មានន័យថា ភាពស៊ីគ្នានៃរបាយអថេរអាចជឿជាក់បាន ។ pseudo-R2 បានពីការប៉ាន់ស្មាន propensity score ក្រោយការផ្គូផ្គង មានកម្រិតទាបជាខ្លាំង (០,០៣%) ធៀបនឹងតម្លៃមុនការផ្គូផ្គង (០,២៩%) ហើយតម្លៃ P-value នៃការធ្វើតេស្តអត្រាជីវភាព ពុំមានគំលាតខ្ពស់ទេ (non-significant) ក្រោយការផ្គូផ្គង ដែលបង្ហាញថា មិនមានភាពខុសប្លែកគ្នាជាលក្ខណៈប្រព័ន្ធទេ ក្នុងរបាយនៃអថេរពាក់ព័ន្ធនានារវាងក្រុមទាំងពីរ ។ លទ្ធផលទាំងនេះបង្ហាញថា លំអៀងក្នុងការជ្រើសរើស បានថយចុះយ៉ាងច្រើនតាមរយៈការផ្គូផ្គងគ្រួសារ ហើយគំរូតាងស្រដៀងគ្នាពីរក្រុម ក៏ត្រូវបានបង្កើតឡើងសម្រាប់តាមដាន និងវាយតម្លៃ ។ តាមនេះ ៩៨គ្រួសារក្នុងតំបន់គំរោង ដែលមានលក្ខណៈមិនស៊ីគ្នាខ្លាំង ត្រូវបានកាត់ចេញ ធ្វើឲ្យយើងទទួលបានគំរូតាងសរុបចំនួន ៧០៣គ្រួសារ ក្រោយការផ្គូផ្គង ។

## សេចក្តីសន្និដ្ឋាន

របាយការណ៍នេះ បង្ហាញនូវសូចនាករមូលដ្ឋានមួយចំនួននៃតំបន់សិក្សាដែលមានសក្តានុពលមួយ នៅតាមខ្សែបណ្តោយគម្រោង GMS-SCC នៅកម្ពុជា ។ វាក៏បានផ្តល់នូវសូចនាករអំពីភាពស្រដៀងគ្នា និងភាពខុសប្លែកគ្នា នៃលក្ខណៈសំគាល់ក្រុមគ្រួសារ ក្នុងតំបន់អនុវត្តគម្រោង និងក្រៅតំបន់គម្រោង មុនការផ្គូផ្គង និងការថយចុះយ៉ាងច្រើននៃភាពខុសប្លែកគ្នាទាំងនោះ បន្ទាប់ពីធ្វើការផ្គូផ្គងរួច ។ មុនការផ្គូផ្គង យើងឃើញមានភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងសូចនាករខាងប្រជាសាស្ត្រ និងសុខុមាលភាព ដែលបង្ហាញពីភាពលំអៀងមួយចំនួនក្នុងការជ្រើសរើសគំរូតាងគ្រួសារ ។

គ្រួសារផ្គូផ្គងស៊ីគ្នា មានលក្ខណៈសំគាល់ស្រដៀងគ្នាក្នុងអថេរ ដែលមានតាំងពីសូចនាករភូមិសាស្ត្រ រហូតដល់សូចនាករសេដ្ឋកិច្ច-សង្គមកិច្ច និងសូចនាករមធ្យោបាយដឹកជញ្ជូន ។ ដោយប្រើវិធីសាស្ត្រ PSM យើងកសាងបានក្រុមគំរូតាងពីរ មានលក្ខណៈសំគាល់ស្រដៀងគ្នា ពោលគឺ ក្រុមក្នុងតំបន់អនុវត្តគម្រោងមាន ៣៨៤គ្រួសារ និងក្រុមក្នុងតំបន់ក្រៅគម្រោងមាន ៣៥៩គ្រួសារ ។ ម្យ៉ាងទៀត មាន ៩៨ គ្រួសារត្រូវបានកាត់ចេញពីក្រុមគំរូតាងក្នុងតំបន់គម្រោង ដោយសារមិនអាចរកគូផ្គូផ្គង ដែលមានលក្ខណៈសំគាល់ស៊ីគ្នាក្នុងក្រុមក្រៅគម្រោងបាន ។ ការជម្រុះនេះ អាចជួយសំចៃចំណាយ និងពេលវេលា ព្រមទាំងសម្រួលការប៉ាន់ស្មានពីផលប៉ះពាល់នៃគម្រោង ដើម្បីបង្កើនប្រសិទ្ធភាពការងារតាមដាន និងវាយតម្លៃ ។

## ឯកសារយោង


Caliendo, M. & S. Kopeinig (2008), "Some Practical Guidance for the Implementation of Propensity Score Matching", *Journal of Economic Surveys,* Vol. 22, No. 1, pp. 31 – 72

Ravallion, M. (2001), "The Mystery of the Vanishing Benefits: An Introduction to Impact Evaluation", *World Bank Economic Review,* Vol. 15, pp. 115 – 140

Theng Vuthy & Kem Sothorn, (forthcoming), The Importance of PSM in Evaluation Studies: A Case Study of Physical Infrastructure in Cambodia, Working Paper (Phnom Penh: CDRI)

World Bank (2002), Socioeconomic Impact Assessment of Rural Roads: Methodology and Questionnaires

Hing Vutha, Saing Chan Hang & Khieng Sothy, (forthcoming). Using Propensity Score Matching to Generate Two Comparable Groups in the Baseline Survey: The Case of GMS Transmission Line Project. Annual Development Review 2010/2011(Phnom Penh: CDRI).

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅអាស៊ីបូព៌ា នៅត្រីមាសទី៣ ឆ្នាំ២០១០ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០១០ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅប្រទេសតណ្ឌូនេស៊ី មានអត្រា ៥,៨% ធៀបនឹង ៦,២% នៅត្រីមាសទី២ ។ កំណើន ផសស នៅម៉ាឡេស៊ីធ្លាក់ចុះមកត្រឹម ៥,៣% និងនៅសង្ហបុរី ត្រឹម ១០,៥% ។ ការនាំចេញសុទ្ធក្នុងត្រីមាសនេះ រួមចំណែកតែ ១១,៤ឯកតាភាគរយប៉ុណ្ណោះ ដល់ ផសស ។ តំរូវការក្នុងស្រុក នៅខ្សោយដដែល ដោយរួមចំណែកតែ ០,៤ឯកតាភាគរយប៉ុណ្ណោះ ដល់កំណើន ។ ម្យ៉ាងទៀត ការថយចុះចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ក៏នាំឲ្យអត្រាកំណើន ផសស នៅសិង្ហបុរី ថយចុះដែរ ។ កំណើន ផសស នៅថៃ ធ្លាក់ចុះមកត្រឹម ៦,៧% និងបណ្តាលមកពីការឡើងថ្លៃប្រាក់បាត ដែលធ្វើឲ្យផលិតផលថៃ ឡើងថ្លៃនៅលើទីផ្សារបរទេស ។ កំណើនការនាំចេញបានថយចុះ ប៉ុន្តែការនាំចូលមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ២៤,៩% ធ្វើឲ្យជញ្ជីងពាណិជ្ជកម្ម មានឱនភាពក្នុងត្រីមាសនេះ ។ ស្តុកទំនិញរបស់សហគ្រាស កើនឡើងយ៉ាងគួរឲ្យកត់សំគាល់ក្នុងត្រីមាសនេះ ។ ការកសាងស្តុកទំនិញ និងការបំពេញស្តុកឡើងវិញ បានជួយជំរុញកំណើន ផសស ។

កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃ ផសស នៅចិន ធ្លាក់ចុះពី ១០,៣% មកត្រឹម ៩,៧% នៅត្រីមាសទី២ តែនៅហុងកុង វាកើនដល់ ៦,៨% ធៀបនឹង ៦,៥% កាលពីត្រីមាសមុន ។ នៅកូរ៉េខាងត្បូង វាធ្លាក់ចុះមកត្រឹម ៤,៥% និងនៅតៃវ៉ាន់ ធ្លាក់មកត្រឹម ៩,៨% ។ ការបង្កើតទុនអចលនៈរួមចំណែក ៤,២ឯកតាភាគរយ ដល់កំណើន ផសស នៅតៃវ៉ាន់ ។ ចំណាយប្រើប្រាស់របស់ឯកជន ដែលជំរុញឡើងដោយសារអ្នកប្រើប្រាស់មានទំនុកចិត្ត និងការធ្លាក់ចុះអត្រាគ្មានការងារធ្វើ មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ៤,៥% និងរួមចំណែក ២,៥ឯកតាភាគរយដល់កំណើន ផសស ។ តំរូវការក្នុងស្រុកសរុប រួមចំណែក ៨,៤ឯកតាភាគរយ ដល់កំណើន ផសស ។ កំណើនការនាំចេញរួមចំណែកយ៉ាងសំខាន់ ដល់កំណើន ផសស នៅតៃវ៉ាន់ ។ ផសស នៅជប៉ុនមានកំណើន ៥% រីឯនៅសហរដ្ឋអាមេរិក កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃ ផសស ធ្លាក់ចុះដល់ ២,៣% ។

## អតិផរណាក្នុងពិភពលោក និង អត្រាប្តូរប្រាក់

នៅឆ្នាំ២០១០ ជប៉ុន ស្ថិតក្រោមសំពាធបរិត្តផរណាអស់៣ត្រីមាសជាបន្តបន្ទាប់មកហើយ នៅពេលដែលអតិផរណាកើនឡើងក្នុងប្រទេសជាច្រើន ។ នៅតណ្ឌូនេស៊ី អតិផរណាមានកម្រិត ៦,២% ធៀបនឹង ៤,៤% នៅត្រីមាសទី២ ដោយសារ សំលៀកបំពាក់ និងការដឹកជញ្ជូនតែងឡើងថ្លៃនៅមុនពិធីបុណ្យ Ramadan ។ អស្ថិរភាពនៃថ្លៃស្បៀងអាហារ និងថ្លៃផ្សេងៗ កំណត់ដោយរដ្ឋ ក៏ជួយបង្កើនសំពាធអតិផរណាដែរ ។ អតិផរណានៅម៉ាឡេស៊ី នៅតែមានកម្រិតទាបត្រឹម ១,៩% និងនៅសិង្ហបុរី វាមានកម្រិត ៣,៤% ។ អតិផរណាលើទំនិញប្រើប្រាស់នៅថៃ នៅថេរត្រឹម ៣,៣% ។ អតិផរណា នៅវៀតណាម មានកម្រិត ៨,៤% ឬទាបជាងត្រីមាសមុន ០,៦% ហើយនៅចិន វាមានកម្រិត ៣,៣% ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃថ្លៃទំនិញប្រើប្រាស់ នៅហុងកុងធ្លាក់ចុះ ២,៣% ។ នៅកូរ៉េខាងត្បូង អតិផរណាមានអត្រា ២,៦% ធៀបនឹង ២,៩% កាលពីត្រីមាសទី២ ហើយនៅតៃវ៉ាន់ វាមានអត្រា ០,៤% ។ ជប៉ុននៅបន្តមានអត្រាអតិផរណាអវិជ្ជមាន -០,៩% រីឯនៅសហរដ្ឋអាមេរិក វាមានកម្រិត ១,២% ។

នៅត្រីមាសទី៣ នេះដែរ ប្រាក់រ៉ូពីយ៉ា ឡើងថ្លៃ ១,៥% ទល់នឹងដុល្លារសហរដ្ឋអាមេរិក បើធៀបនឹងត្រីមាសមុន ។ ប្រាក់រីងហ្គីតឡើងថ្លៃ ២,៨% រីឯ ដុល្លារសិង្ហបុរី ប្រាក់យ៉ន់ និងដុល្លារតៃវ៉ាន់ នៅថេរ ប៉ុន្តែប្រាក់បាតថៃឡើងថ្លៃ ២,២% ស្របពេលដែល ប្រាក់ដុងវៀតណាម ចុះថ្លៃ ២,៦% ។ ដុល្លារហុងកុង ឡើងថ្លៃ ០,១% ទល់នឹងដុល្លារសហរដ្ឋអាមេរិក ខណៈពេលដែលប្រាក់វ៉ុនកូរ៉េខាងត្បូង ចុះថ្លៃ ១,៤% ហើយប្រាក់អឺរ៉ូ ឡើងថ្លៃ ២,៥% និងប្រាក់យ៉េន ឡើងថ្លៃ ៧,០% ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ពោត(US No.2)ឡើងថ្លៃ ១២% ដល់ ១៧៦ដុល្លារ/តោន ធៀបនឹងត្រីមាសមុន ។ សណ្តែកសៀង ឡើងថ្លៃ ១០% ដល់ ៤០៧ដុល្លារ/តោន ។ កៅស៊ូ SMR5 ឡើងថ្លៃ ៣% ដល់ ៣១៧៦ដុល្លារ/តោន អង្ករ (Thai 100%) ឡើងថ្លៃ ១,៥% ដល់ ៤៦៨ដុល្លារ/តោន ។ ប្រេងឆៅធ្លាក់ថ្លៃ ២,៧% មកត្រឹម ៧៥ដុល្លារ/ធុង ប្រេងសាំងធ្លាក់ថ្លៃ ២,៧% មកត្រឹម ០,៥១ដុល្លារ/លីត្រ និងប្រេងម៉ាស៊ូតធ្លាក់ថ្លៃ ៥,៣% មកត្រឹម ០,៥៤ ដុល្លារ/លីត្រ ។

*រៀបរៀងដោយ ស្រី បុប្ផារ័ត្ន*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 | 5.8 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9 | 8.9 | 5.3 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4 | 18.7 | 10.5 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.2 | 6.7 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | 5.8 | 6.4 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1 | 10.7 | 11.9 | 10.3 | 9.7 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0 | 6.5 | 6.8 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 | 4.5 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4 | 14.6 | 12.9* | 9.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | - | - | - |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 5.5* | 3.5* | 5.0 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 2.6* | 2.8* | 2.9* | 2.3 |

*Sources: International Monetary Fund, Economist and countries' statistic offices. * Updated data*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 | 6.2 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.6* | 1.9 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.1* | 3.4 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 3.3* | 3.3 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | 9.0 | 8.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1 | 2.7 | 3.3 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.6 | 2.3 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 | 2.9 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3* | 1.3 | 1.1 | 0.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 | - |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 | -0.9 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 | 1.2 |

*Sources: International Monetary Fund, Economist and National Institute of Statistics. * Updated data*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.30 | 4092.50 | 4103.20 | 4062.70 | 4054.20 | 4108.00 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 | 4236.69 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938.00 | 9705.00 | 9134.00 | 9419.00 | 9699.00 | 11630.80 | 10225.00 | 9887.00 | 9472.44 | 9266.93 | 9,132.00 | 8995.11 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.70 | 3.30 | 3.30 | 3.60 | 3.50 | 3.50 | 3.40 | 3.37 | 3.24 | 3.15 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.51 | 1.45 | 1.44 | 1.39 | 1.40 | 1.36 | 1.36 |
| ថៃ (បាត) | 40.20 | 40.20 | 37.90 | 32.22 | 33.36 | 35.29 | 33.98 | 33.96 | 33.30 | 32.90 | 32.33 | 31.63 |
| វៀតណាម (ដុង) | 15777.00 | 15859.00 | 15994.00 | 16030.00 | 16382.00 | 16954.00 | 17801.00 | 17841.00 | 18472.00 | 18825.67 | 18993.00 | 19485.00 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ័ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.84 | 6.83 | 6.83 | 6.83 | 6.83 | 6.77 | 6.77 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.75 | 7.76 | 7.78 | 7.77 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145.00 | 1024.00 | 955.00 | 929.04 | 1137.23 | 1412.50 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 | 1182.41 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.60 | 32.10 | 32.50 | 32.85 | 31.54 | 34.00 | 33.10 | 32.77 | 32.29 | 31.93 | 31.90 | 31.90 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.70 | 0.84 | 0.76 | 0.71 | 0.70 | 0.68 | 0.72 | 0.79 | 0.77 |
| ជប៉ុន (យ៉េន) | 108.20 | 110.20 | 116.40 | 117.80 | 102.46 | 93.72 | 95.95 | 93.58 | 89.78 | 90.73 | 92.20 | 85.74 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០១០(មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 183.12 | 171.16 | 146.85 | 168.13 | 162.88 | 157.41 | 176.13 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 636.53 | 719.35 | 659.16 | 732.33 | N/A | N/A | N/A |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 522.13 | 499.45 | 307.31 | 569.00 | 565.67 | 461.33 | 468.33 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 434.40 | 420.10 | 411.18 | 390.43 | 372.68 | 370.95 | 406.88 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 33.50 | 50.14 | 61.58 | 69.25 | 95.44 | 42.34 | 57.46 | 68.32 | 73.86 | 75.73 | 77.00 | 74.91 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 42.19 | 47.70 | 53.58 | 62.22 | 31.97 | 43.11 | 46.92 | 49.64 | 53.87 | 54.43 | 51.54 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.20 | 34.17 | 40.51 | 46.46 | 51.03 | 53.87 | 55.13 | 53.64 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## ស្ថានភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៣ ឆ្នាំ២០១០ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើនឡើង ៤៨% ធៀបនឹងត្រីមាសមុន ដោយសារអនុមតិសម្រាប់វិស័យកសិកម្ម កើន ៥៧១% ដល់ ២៧៨,០លានដុល្លារ ។ គម្រោងកសិឧស្សាហកម្មដែលបានអនុម័ត មានចំនួន ៤ មានតម្លៃ ១៧៦,៩លានដុល្លារ ។ អនុមតិសម្រាប់ដំណាំកៅស៊ូ កើនដល់ ៦ គម្រោង មានតម្លៃសរុប ១០១,១លានដុល្លារ ។ អនុមតិសម្រាប់វិស័យឧស្សាហកម្ម ធ្លាក់ចុះ ១៩% មកត្រឹម ៤៤,៣លានដុល្លារ ប៉ុន្តែអនុមតិសម្រាប់ផ្នែកកាត់ដេរ កើន ៤៧% ដល់ ៣១,៤លានដុល្លារ ។ គ្មានអនុមតិសម្រាប់វិស័យសេវាកម្មទេ នៅត្រីមាសនេះ ។

នៅត្រីមាសទី៣ នេះដែរ ភ្ញៀវមកដល់កម្ពុជា កើន ៨,៣% ធៀបនឹងខែមុន ដល់ ៥៨២.០២៤នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១១% ដល់ ២៨៨.២៥៤នាក់ ហើយតាមផ្លូវគោក និងផ្លូវទឹក កើន ៦,២% ដល់ ២៩៣.៧៧០នាក់ ។ ក្នុងចំណោមប្រទេសក្នុង អាស៊ាន តំបន់អាស៊ី និងអាស៊ីប៉ាស៊ីហ្វិក ប្រទេសដែលមានភ្ញៀវចូលមកកម្ពុជាច្រើនជាងគេ គឺ វៀតណាម (១២៥.៦១៧នាក់) កូរ៉េ (៦៣.៣៣៥នាក់) និង ចិន (៤៣.៤៩៤នាក់)។

ការនាំចេញសរុបនៅត្រីមាសទី៣ កើនឡើង ៥៧% ធៀបនឹងត្រីមាសមុន ដល់ ៩០៣,៩លានដុល្លារ ក្នុងនេះ ការនាំចេញសំលៀកបំពាក់មានដល់ ៨៩,២% ។ ការនាំចេញទៅសហរដ្ឋអាមេរិក កើនឡើង ៥៧% ដល់ ១៣៤លានដុល្លារ ទៅសហភាពអឺរ៉ុប កើន ៤៣,៧% ដល់ ១៦៧លានដុល្លារ ទៅប្រទេសជប៉ុន កើន ៣៩% ដល់ ២១៤លានដុល្លារ ហើយទៅប្រទេសផ្សេងៗទៀត កើន ៤៨% ដល់ ១៦៥លានដុល្លារ ។ ការនាំចេញទៅប្រទេសអាស៊ាន កើនឡើង ២៣៥% ដល់ ១២៦លានដុល្លារ ។ ការនាំចេញផលិតផលកសិកម្ម កើន ៤០% ដល់ ៩៨លានដុល្លារ ក្នុងនេះ ការនាំចេញកៅស៊ូ កើន ៨៤% ការនាំចេញឈើ កើន ៩៦% ប៉ុន្តែ ការនាំចេញត្រី ធ្លាក់ចុះ ១១% ។ ការនាំចេញផ្សេងៗទៀត កើនឡើង ២៤% ។ ការនាំចូលសរុប កើនឡើង ៨% ។ ការនាំចូលប្រេងសាំង កើន ២៣% ប៉ុន្តែការនាំចូលប្រេងម៉ាសូត ធ្លាក់ចុះ ១៤% ។ ការនាំចូលសម្ភារៈសំណង់ កើនឡើង ២១% និងការនាំចូលផ្សេងៗទៀត កើនឡើង ១០៨% ។

## ហិរញ្ញវត្ថុសាធារណៈ

ចំណូលចរន្ត កើនឡើង ៧,៥% ធៀបនឹងខែមុន ដល់ ១៤៣១៣ពាន់លានរៀល ។ ចំណូលពន្ធ កើន ៧,១% ដោយសារកំណើនចំណូលពន្ធក្នុងស្រុក ៣,០% និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ២២% ។ ចំណូលមិនមែនពន្ធ កើន ១០% ប៉ុន្តែចំណូលមូលធន ធ្លាក់ចុះ ៥៣% ។ ចំណាយមូលធន ធ្លាក់ចុះ ២,៨% ប៉ុន្តែចំណាយចរន្ត កើនឡើង ២៩% ។ ហិរញ្ញប្បទានបរទេសនៃថវិកាក្នុងត្រីមាសនេះ ធ្លាក់ចុះ ៤៥% ប៉ុន្តែហិរញ្ញប្បទានក្នុងស្រុក កើនឡើង ៧៧% ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើន ១,៨% ធៀបនឹងឆ្នាំមុន ដោយសារជាសំខាន់ ថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើន ១,៩% និងថ្លៃដឹកជញ្ជូន កើន ៣,២% ។ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៧% ទល់នឹងដុល្លារអាមេរិក ដោយប្តូរបាន ៤២៣៦,៧រៀល/ដុល្លារ និងធ្លាក់ថ្លៃ ៦,៥% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ៣,២% ទល់នឹងប្រាក់ដុងវៀតណាម ។ មាស ឡើងថ្លៃ ៥% ដល់ ១៥០ដុល្លារ/ជី ។ ប្រេងម៉ាស៊ូត ឡើងថ្លៃ ២,៦% ហើយ ប្រេងសាំង ឡើងថ្លៃ ១,៣% ធៀបនឹងត្រីមាសមុន ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី៣ សាច់ប្រាក់ងាយស្រួលសរុប (M2) កើន ៣,៤% ដល់ ១៨.៨៨៨ពាន់លានរៀល ។ ប្រាក់រៀលចរាចរ ធ្លាក់ចុះមកត្រឹម ២៩១៧ពាន់លានរៀល ហើយបញ្ញើជាប្រាក់រៀល ធ្លាក់ចុះមកត្រឹម ១៤៥ពាន់លានរៀល ។ ស្របពេលជាមួយគ្នានេះដែរ បញ្ញើជារូបិយវត្ថុបរទេស កើនដល់ ១៥.៣៩៥ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៣៤% ដល់ ១៦.៩០៣ពាន់លានរៀល ដោយសារមានកំណើនទ្រព្យសកម្មបរទេស ដល់ ១៨.៩៩៥ពាន់លានរៀល និងកំណើនបំណុលបរទេស ដល់ ២០៩២ពាន់លានរៀល ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ១១% ដល់ ១៩៨៥ពាន់លានរៀល ។ ឥណទានក្នុងស្រុក កើនដល់ ១០.៣៦១ពាន់លានរៀល ហើយបំណុលផ្សេងទៀត កើនដល់ ៨៣៧៧ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ

ក្នុងខែវិច្ឆិកា ២០១០ ក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ក្រុម មាន ៩ក្រុម មានចំណូលប្រចាំថ្ងៃពិតកើនឡើងបន្តិចបន្តួច ធៀបនឹងខែវិច្ឆិកា ២០០៩ ហើយ ១ក្រុមទៀត គឺក្រុមកម្មករសំណង់មានជំនាញ បានធ្លាក់ចុះចំណូល ។

អ្នកធាក់ស៊ីក្លូ ៤០នាក់ ដែលបានជ្រើសរើសសម្រាប់ធ្វើសម្ភាសន៍ អំពីស្ថានភាពរស់នៅប្រចាំថ្ងៃ បានឲ្យដឹងថា ចំណូលរបស់ពួកគេ កើនដល់ ៨៩៤២រៀល/ថ្ងៃ ឬ កើនឡើង ២៤% បើធៀបនឹងខែវិច្ឆិកា ២០០៩ ។ ប៉ុន្តែចំណាយប្រចាំថ្ងៃ

របស់ពួកគេ ក៏កើន ២៥% ដែរ ដល់ ៥០៩២រៀល/ថ្ងៃ ។ ក្នុងចំណោមអ្នកជាក់ស៊ីក្លូដែលឆ្លើយសម្ភាសន៍ មានតែ ១៣% ប៉ុណ្ណោះ ដែលជួលកន្លែងស្នាក់នៅ ក្រៅពីនោះស្នាក់នៅតាមចិញ្ចើមថ្នល់ វត្តអារាម ផ្ទះរបស់ម្ចាស់ស៊ីក្លូដែលខ្លួនជួល និងជាមួយសាច់ញាតិ ។ល។

នៅខែវិច្ឆិកានេះដែរ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់បន្លែ កើនដល់ ៩០០៦រៀល/ថ្ងៃ ឬ កើន ២២% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៩ ។ អ្នកឆ្លើយសម្ភាសន៍ ៤៥% ប្រាប់ថា អាចបង្កើនប្រាក់ចំណូលរបស់ខ្លួនបាន ប្រសិនបើពួកគេមានមូលធនគ្រប់គ្រាន់ ដើម្បីវិនិយោគក្នុងជំនួញរបស់ខ្លួន ។ ចំណាយប្រចាំថ្ងៃពិតរបស់ពួកគេ កើនឡើងបន្តិចបន្តួចត្រឹម ០,៤% ដល់ ៤១៨៣រៀល/ថ្ងៃ ។ អ្នកឆ្លើយសម្ភាសន៍ ២៧% មកពីទីក្រុងភ្នំពេញ ២០% មកពីខេត្តព្រៃវែង និងស្វាយរៀង និង ១៣% មកពីខេត្តកណ្តាល ។

ចំណូលរបស់អ្នករើសអេតចាយ កើនខ្លាំង (៤៩% ធៀបនឹងឆ្នាំ២០០៩) ដល់ ៦៧៦៦រៀល/ថ្ងៃ ដោយសារការឡើងថ្លៃរបស់អេតចាយ បានជួយប៉ះប៉ូវដល់កំណើនចំនួនអ្នករើសអេតចាយ និងការធ្លាក់ចុះប្រភពរបស់អេតចាយ ។ មានអ្នករើសអេតចាយតែ ២០% ប៉ុណ្ណោះ ដែលមានជំរកផ្ទាល់ខ្លួន ក្រៅពីនោះសុទ្ធតែមកពីតាមខេត្ត ហើយជួលផ្ទះគេនៅទីក្រុងភ្នំពេញ ។ ពួកគេចំណាយជាមធ្យម ៣៨៤៦រៀល/ថ្ងៃ ដែលជាកំណើនយ៉ាងខ្ពស់ដល់ ៨៣% បើធៀបនឹងឆ្នាំមុន ។ អ្នករើសអេតចាយ ៩៧% មិនមានប្រាក់សល់សម្រាប់សន្សំទុកទេ ។

ចំណូលរបស់កម្មកររោងចក្រកាត់ដេរ កើន ៦,២% ដល់ ៧៩៤៤រៀល/ថ្ងៃ ។ អ្នកឆ្លើយសម្ភាសន៍ ៨៩% ធ្វើការ ៦ថ្ងៃ/សប្តាហ៍ និងមានម៉ោងបន្ថែមជារឿយៗ ។ ចំណាយប្រចាំថ្ងៃជាមធ្យមរបស់កម្មករកាត់ដេរ ធ្លាក់ចុះ ៥% ធៀបនឹងឆ្នាំមុន មកត្រឹម ៤៦៣៤រៀល/ថ្ងៃ ។ កម្មករកាត់ដេរ ៦៤% សន្សំប្រាក់បានតិចតួចណាស់ ។

នៅខែវិច្ឆិកា ២០១០ ចំណូលរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន មកត្រឹម ១២៣៧៦រៀល/ថ្ងៃ ដោយសារ កំណើនចំនួនកម្មករ វាលឿនជាងកំណើនសកម្មភាពសំណង់ ។ ចំណាយប្រចាំថ្ងៃរបស់ពួកគេធ្លាក់ចុះ ៨,៦% មកត្រឹម ៣៤៨៤រៀល/ថ្ងៃ ។ កម្មករសំណង់មានជំនាញ ២៤% មិនអាចរកប្រាក់បានសល់សម្រាប់សន្សំទុកទេ ។

*រៀបរៀងដោយ*
*ស្រ៊ី បុប្ផារ័ត្ន និង ប៊ុនដូរីណា*


## Cambodia Development Review—2011 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒ Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

### តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 12.3 | 26.8 | 498.0 | 135.6 | 92 | 175.3 | 0.0 | 176.1 | 94.4 | 165.7 | 41.4 | 278.0 |
| ឧស្សាហកម្ម | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 39.4 | 60.6 | 685.5 | 247.7 | 54.5 | 44.3 |
| *កាត់ដេរ* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *35.0* | *21.9* | *14.2* | *13.1* | *21.3* | *29.3* |
| សេវាកម្ម | 91.8 | 155.5 | 2939.1 | 1742.5 | 10003.2 | 495.6 | 0.0 | 150.2 | 3475.8 | 89.5 | 121.6 | 0.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *0.0* | *150.2* | *0.0* | *3.78* | *14.0* | *0.0* |
| សរុប | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 39.4 | 386.3 | 4255.7 | 502.9 | 217.5 | 322.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -41.2 | -95.7 | 882.0 | 1001.7 | -91.2 | -56.8 | 48.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -5.6 | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -99.0 | -91.5 | 169.3 | -59.8 | 452.0 | -16.6 |

*Including expansion project approvals. Source: Cambodian Investment Board*

### តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 6.7 | 2.2 | 9.8 | 5.1 | 7.5 | 14.13 |
| ផ្ទះល្វែង | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 18.9 | 6.3 | 28.0 | 11.1 | 127.2 | 25.32 |
| ផ្សេងៗ | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 36.7 | 12.2 | 29.0 | 35.2 | 67.4 | 38.90 |
| សរុប | 263.5 | 358.8 | 323.3 | 635.8 | 1117.0 | 181.1 | 62.3 | 20.7 | 66.8 | 51.4 | 202.1 | 78.35 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -48.5 | -65.6 | -66.8 | 222.7 | -23.1 | 293.2 | 3776.8 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 32.5 | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -55.8 | -95.7 | -81.0 | -71.6 | 224.4 | 37750.2 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

### តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 221.2 | 247.2 | 308.1 | 371.5 | 260.9 | 288.3 |
| តាមផ្លូវគោក និងទឹក | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 243.0 | 240.2 | 279.5 | 312.2 | 276.6 | 293.8 |
| សរុប | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 464.2 | 487.4 | 587.6 | 683.7 | 537.5 | 582.0 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 7.7 | -25.4 | 5.0 | 20.6 | 16.4 | -21.4 | 8.3 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 50.5 | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 2.2 | 9.4 | 1.7 | 9.9 | 15.8 | 19.4 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 2189.4 | 2452.5 | 2920.4 | 3160.1 | 3206.9 | 568.94 | 558.11 | 618.84 | 648.87 | 496.06 | 575.40* | 903.90 |
| ក្នុងនេះ៖ សំលៀកបំពាក់* | 2108.1 | 2352.8 | 2810.8 | 3050.2 | 3097.8 | 462.2 | 492.4 | 535.5 | 579.3 | 433.3 | 505.4 | 806.0 |
| *- សហរដ្ឋអាមេរិក* | *1281.7* | *1555.6* | *1851.7* | *1959.9* | *1913.0* | *88.0* | *88.1* | *89.3* | *80.1* | *76.7* | *85.2* | *134.1* |
| *- សហភាពអឺរ៉ុប* | *593.1* | *506.9* | *603.0* | *660.9* | *693.4* | *108.6* | *128.3* | *125.7* | *113.8* | *102.5* | *115.9* | *166.6* |
| *- អាស៊ាន* | *55.4* | *70.7* | *80.4* | *90.3* | *99.6* | *51.0* | *55.1* | *62.1* | *152.1* | *42.7* | *37.5* | *125.7* |
| *- ជប៉ុន* | *23.0* | *25.0* | *40.6* | *30.1* | *26.5* | *110.9* | *112.8* | *149.3* | *128.3* | *124.1* | *154.8* | *214.4* |
| *- ប្រទេសផ្សេងៗ* | *154.9* | *194.6* | *235.1* | *309.0* | *365.3* | *103.7* | *108.1* | *109.1* | *105.0* | *87.3* | *112.0* | *165.2* |
| កសិកម្ម | 81.3 | 99.7 | 109.6 | 109.9 | 109.1 | 106.74 | 65.71 | 83.34 | 69.57 | 62.76 | 70.00* | 97.9 |
| *- កៅស៊ូ* | *38.3* | 36.7 | *41.5* | *41.0* | 35.8 | *11.79* | *8.27* | *15.08* | *16.49* | *11.94* | *13.81* | 25.4 |
| *- ឈើ* | *11.1* | 10.3 | 8.6 | 8.7 | 3.4 | *0.55* | *0.5* | *0.64* | *1.83* | *2.75* | *4.48* | 8.8 |
| *- ត្រី* | *10.6* | 10.1 | 5.9 | 3.2 | 2.3 | *0.83* | *0.85* | *1.11* | *1.2* | *0.81* | *0.56* | 0.5 |
| *- ផ្សេងៗ* | *21.3* | 42.6 | 53.6 | 57.0 | 67.6 | *93.57* | *56.09* | *66.51* | *50.05* | *47.26* | *51.15* | 63.2 |
| ការនាំចូលសរុប* | 2148.9 | 2513 | 512.2 | 554.8 | 1010.9 | 173 | 177.8 | 148.8 | 133.2 | 139.3 | 174.8 | 188.7 |
| ក្នុងនេះ៖ សាំង | 30.2 | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 15.6 | 19.3 | 19.4 | 22.0 | 17.3 | 21.2 |
| ម៉ាស៊ូត | 109.4 | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 40.0 | 46.0 | 43.1 | 44.7 | 49.6 | 42.6 |
| សម្ភារៈសំណង់ | 95.3 | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 14.8 | 15.7 | 13.3 | 14.5 | 13.5 | 16.3 |
| ផ្សេងៗ | 1914.0 | 2245 | 303.9 | 304.3 | 749.5 | 108.2 | 107.4 | 67.8 | 57.4 | 58.1 | 94.4 | 108.6 |
| ជញ្ជីងពាណិជ្ជកម្ម | 40.5 | -60.5 | 2408.2 | 2605.3 | 2196 | 395.94 | 380.31 | 470.04 | 515.67 | 356.76 | 344.41 | 715.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -16.0 | 6.5 | 8.8 | 8.2 | -25.2 | 16.6 | 59.5 |
| ការនាំចេញសរុប | - | - | - | - | - | -1.7 | -1.9 | 10.9 | 4.9 | -23.6 | 4.7 | 57.1 |
| ការនាំចូលសរុប | - | - | - | - | - | -6.5 | 2.8 | -16.3 | -10.5 | 4.6 | 25.5 | 8.0 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 23.4 | 11.6 | 19.5 | 8.5 | 1.6 | -5.4 | -7.0 | -11.4 | 5.3 | -6.3 | 2.6 | 50.5 |
| ការនាំចេញសរុប | 22.5 | 12.0 | 19.1 | 8.2 | 1.5 | 12.1 | -5.5 | -3.0 | 12.1 | -12.8 | -7.0 | 46.1 |
| ការនាំចូលសរុប | 17.8 | 16.9 | -79.6 | 8.3 | 82.2 | 30.9 | -67.5 | 0.0 | -28.0 | -19.5 | -1.7 | 26.8 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site). *Updated data*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៤-១០ (ពាន់លានរៀល)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 2126.0 | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 |
| ចំណូលចរន្ត | 2107.0 | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 |
| ចំណូលពន្ធ | 1577.0 | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 |
| ពន្ធក្នុងស្រុក | - | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 |
| ចំណូលមិនមែនពន្ធ | 530.0 | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 |
| លក់ទំនិញ និងសេវា | - | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 |
| ចំណូលជាមូលធន | 19.0 | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 |
| ចំណាយសរុប | 2932.0 | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 |
| ចំណាយជាមូលធន | 1163.0 | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 |
| ចំណាយចរន្ត | 1769.0 | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 |
| បៀវត្សរ៍ | 640.0 | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 |
| សមតុល្យជាទូទៅ | -806.0 | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -875.6 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 864.0 | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 |
| ហិរញ្ញប្បទានក្នុងស្រុក | 148.0 | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 |

*Source: MEF web site.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 | 1.8 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -5.2 | -2.7 | 1.8 | 7.8 | 3.6 | 1.9 |
| - ដឹកជញ្ជូន | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -16.5 | -13.8 | 2.4 | 12.9 | 8.7 | 3.2 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4128.6 | 4164.4 | 4157.3 | 4180.1 | 4209.0 | 4236.7 |
| រៀលក្នុង ១ បាតថៃ | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 119.2 | 122.9 | 126.0 | 127.0 | 129.9 | 138.3 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.3 | 23.5 | 23.0 | 22.3 | 22.1 | 21.4 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 110.7 | 123.2 | 133.8 | 133.9 | 142.9 | 150.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3056.9 | 3867.0 | 3381.9 | 3599.5 | 3835.1 | 3936.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3452.4 | 3371.1 | 3940.2 | 4163.0 | 4358.7 | 4415.5 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៤-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4797.0 | 5475.0 | 7224.0 | 10735.0 | 10345.0 | 11222.0 | 12611.0 | 13869.0 | 14655.0 | 15514.6 | 12610.9 | 16903.0 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -467.0 | -450.0 | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -209.0 | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2120.4 |
| ឥណទានដល់ផ្នែកឯកជន | 1817.0 | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10129.0 | 10127.0 | 10532.0 | 11146.7 | 11859.1 | 12479.8 |
| រូបិយវត្ថុទូទៅ M2 | 4330.0 | 5025.0 | 6942.0 | 11311.0 | 11858.0 | 12488.0 | 13859.0 | 14912.0 | 16228.0 | 17234.5 | 18267.1 | 18887.8 |
| រូបិយវត្ថុ M1 | 1153.0 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 |
| រូបិយវត្ថុផ្សេងៗ | 3177.0 | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11164.0 | 12139.0 | 13108.0 | 14086.0 | 15152.0 | 15826.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 30.0 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 6.0 | 3.4 |
| រូបិយវត្ថុ M1 | 23.0 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | -1.1 | -1.7 |
| រូបិយវត្ថុផ្សេងៗ | 32.8 | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 7.6 | 4.4 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2007 | 2008 | 2009 | | 2010 | | | | 2010 | | |
| | | វិច្ឆិកា | វិច្ឆិកា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកដាក់ស៊ីក្លូ | 8075 | 9675 | 12628 | 7738 | 7194 | 9413 | 9570 | 8393 | 8942 | 7.6 | 8.5 | 24.3 |
| អ្នកលីសែង | 8588 | 9119 | 9005 | 8159 | 9243 | 9953 | 9340 | 10500 | 10174 | -9.5 | 28.7 | 10.1 |
| អ្នកលក់បន្លែតូចតាច | 8220 | 8552 | 9926 | 8323 | 7388 | 7826 | 8062 | 8380 | 9006 | -17.5 | 0.7 | 21.9 |
| អ្នករើសអេតចាយ | 5422 | 5727 | 4652 | 7087 | 4535 | 6238 | 7407 | 6452 | 6766 | 11.6 | -9.0 | 49.2 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4482 | 4643 | 4327 | 4574 | 5380 | 5131 | 5380 | 6418 | 5562 | 23.8 | 40.3 | 3.4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 6426 | 8697 | 5785 | 4834 | 5358 | 6260 | 6177 | 5015 | -12.2 | 6.8 | 3.7 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 7240 | 6554 | 7410 | 7484 | 7557 | 7491 | 8470 | 7944 | 12.0 | 14.3 | 6.2 |
| អ្នករត់ម៉ូតូឌុប | 10634 | 11872 | 15691 | 9569 | 9369 | 11302 | 10274 | 10544 | 10494 | -15.9 | 10.2 | 12 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 7777 | 8779 | 9444 | 7857 | 7699 | 9013 | 11722 | 9838 | -9.5 | -7.5 | 25.2 |
| កម្មករសំណង់មានជំនាញ | 11154 | 11286 | 12710 | 11918 | 12571 | 11924 | 11928 | 11722 | 12376 | -12.9 | -1.6 | -1.6 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៨* **ព័ត៌មានថ្មីពី...**

ការកាត់បន្ថយភាពក្រីក្រ អភិបាលកិច្ចនិងរបៀបរៀបចំស្ថាប័ន សមភាពយេនឌ័រ និងការបង្ការនិងដោះស្រាយទំនាស់ ។ ឯកសារក៏មានបញ្ជាក់ពីសំណួរស្រាវជ្រាវជាអាទិភាព សម្រាប់កម្មវិធីនីមួយៗដែរ ។

ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ របស់ CDRI បានរចនារៀបចំឡើងពាក់ព័ន្ធនឹងកម្មវត្ថុចំនួន៤ ដោយមានបញ្ជាក់ពីយុទ្ធសាស្ត្រ និងសូចនាករវាស់វែងលទ្ធផល សម្រាប់កម្មវត្ថុនីមួយៗ៖

១) ធ្វើការស្រាវជ្រាវឯករាជ្យ ពិតប្រាកដ មានគុណភាពខ្ពស់ ពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍ ព្រមទាំងញ៉ាំងឲ្យចំណេះដឹងអភិវឌ្ឍន៍ទាំងនេះ បានទៅដល់អ្នកបង្កើតគោលនយោបាយ អ្នកមានឥទ្ធិពល អ្នកពាក់ព័ន្ធ និងមានផលប្រយោជន៍កាន់តែច្រើន ។

២) រួមចំណែកយ៉ាងច្រើន លើកកំពស់វប្បធម៌ស្រាវជ្រាវអភិវឌ្ឍន៍ជាតិ សមត្ថភាពបុគ្គលនិងស្ថាប័ននៅប្រទេសកម្ពុជា ព្រមទាំងការយល់ដឹងរបស់សហគមន៍អំពីបញ្ហាអភិវឌ្ឍន៍ ។

៣) ប្រកាន់ខ្ជាប់របៀបរបបល្អ ដើម្បីសម្រេចបានការស្រាវជ្រាវមានគុណភាពខ្ពស់ តាមរយៈការកែលំអជាបន្តបន្ទាប់នូវការគ្រប់គ្រង សកម្មភាពស្រាវជ្រាវ ប្រព័ន្ធគាំទ្រ និងការពិនិត្យតាមដានយ៉ាងសក្តិសិទ្ធិ ។

៤) កសាងអនាគត CDRI ឲ្យកាន់តែមានចីរភាពល្អក្នុងលក្ខណៈជាស្ថាប័នស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍ ឈានមុខរបស់កម្ពុជា តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ការជំរុញដំណើរការខ្មែរភាវូបនីយកម្ម ការកសាងសមត្ថភាពថ្នាក់គ្រប់គ្រង និងបុគ្គលិក CDRI និងការកៀងគរប្រមូលធនធានមានប្រសិទ្ធភាព ។

## ផ្នែកស្រាវជ្រាវ

វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវ និងសកម្មភាពទាក់ទិនដូចតទៅ ក្នុងរយៈពេលពីខែមករា ដល់ មីនា ២០១១ ។

### *កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រត្តិបត្តិការក្នុងតំបន់*

កម្មវិធីនេះ បានអនុវត្តគម្រោងស្រាវជ្រាវចំនួន ៨ ។ គម្រោង "អង្កេតពលករងាយរងគ្រោះ" និង "អង្កេតថ្លៃទំនិញតាមខេត្ត" កំពុងលូតលាស់ទៅមុខយ៉ាងល្អ ។ របាយការណ៍ស្តីពី "ភាពក្រីក្រ និងចំណងទាក់ទងជាមួយបរិស្ថាន៖ ករណីសិក្សានៅជនបទកម្ពុជា" ដែលជាសមាសភាគទីពីរនៃគម្រោងបណ្តាញភាពក្រីក្រ និង "បញ្ហាប្រឈមចំបងៗលើមាគ៌ាលូតលាស់សេដ្ឋកិច្ច៖ ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរដ្ឋាភិបាល" ព្រមទាំងរបាយការណ៍ "ការស្វែងរកសក្តានុពលកំណើន និងការវាយតម្លៃពីសក្តានុពលកំណើននៅកម្ពុជា" បានទទួលគំនិតយល់ស្របពីម្ចាស់ជំនួយ (ADB និង KDI) ។ របាយការណ៍ព្រាងដំបូងសម្រាប់គម្រោង "ចរន្តពលករខុសៗគ្នា តម្រូវការ និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មអន្តរជាតិនៅអាស៊ាន" គ្រោងចប់រួចរាល់ សម្រាប់ការពិនិត្យឡើងវិញនៅចុងខែមីនា ២០១១ ហើយក្រុមការងារបានទៅចូលរួមសិក្ខាសាលាបច្ចេកទេសនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន កាលពីខែមករា ។ របាយការណ៍បច្ចេកទេស ស្តីពី វិធីសាស្ត្រធ្វើរោគវិនិច្ឆ័យលើកំណើន ដែលជាជំហានដំបូងនៃគម្រោង "ការធ្វើរោគវិនិច្ឆ័យលើកំណើន" បានបញ្ចប់ប្រកបដោយជោគជ័យ ហើយជំហានទី២ កំពុងដំណើរការទៅមុខ ។ របាយការណ៍ព្រាងដំបូងនៃគម្រោង "ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា" បានប្រគល់ជូនអង្គការស្បៀង និងកសិកម្ម (FAO) ដើម្បីសុំមតិបន្ថែម ។ អត្ថបទពីរ គឺ "ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍ពលកម្មឆ្លងកាត់ព្រំដែនក្នុងមហាអនុតំបន់មេគង្គ (GMS)" និង "ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនទៅលើការកាត់បន្ថយភាពក្រីក្រនៅ GMS" ដែលជាការសិក្សាលើកទី៦ និងទី៨ អំពីប្រទេស GMS ធ្វើឡើងដោយបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) កំពុងរៀបចំបង្ហើយសម្រាប់ការបោះពុម្ពផ្សាយជាអន្តរជាតិដោយវិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (ISEAS) ។ បច្ចុប្បន្ន CDRI កំពុងស្វែងរកដៃគូសហការជាយុទ្ធសាស្ត្រ ដើម្បីជួយទ្រទ្រង់ DAN ចាប់ពីឆ្នាំ២០១១ តទៅ ។ ក្រុមស្រាវជ្រាវគម្រោង "វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" បានជ្រើសរើស ២ភូមិ បន្ថែមទៀតសម្រាប់ការសិក្សា ហើយអង្កេតនឹងធ្វើឡើងក្នុងខែមីនា ។ កិច្ចសន្យាសម្រាប់គម្រោង "ការវិភាគពីភាពក្រីក្រពុំរ៉ៃនៅជនបទកម្ពុជា៖ ភស្តុតាងបានពីទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់" ដែលឧបត្ថម្ភដោយបណ្តាញអភិវឌ្ឍន៍អាស៊ីបូព៌ា បានចុះហត្ថលេខារួចរាល់ហើយ ។

### កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណ:

បច្ចុប្បន្ន កម្មវិធីនេះកំពុងអនុវត្តគម្រោងចំនួន ៦ ។ គម្រោង "ការប្រែប្រួលក្នុងសេដ្ឋកិច្ចកម្ពុជា៖ ការពិនិត្យវិភាគពីសមត្ថភាពរដ្ឋ" ព្យាយាមវែកញែក កំណត់ និងវាយតម្លៃពី សមត្ថភាព និងស្ថានភាពបច្ចុប្បន្នរបស់រដ្ឋ ស្វែងរកកត្តាដែលជះឥទ្ធិពលលើសមត្ថភាពរដ្ឋ និងផ្តល់គំនិតពីមធ្យោបាយកែលំអសមត្ថភាពរដ្ឋ ហើយសព្វថ្ងៃក្រុមការងារ កំពុងប្រមូលព័ត៌មានអំពីស្ថានភាពពិតជាក់ស្តែង ។ គម្រោង "ការវិភាគពីវិមជ្ឈការ និងវិសហមជ្ឈការ" កំពុងកំណត់មើលពីនិន្នាការ និងអនាគត នៃកំណែទម្រង់ D&D ក្នុងបរិបទមានប្រព័ន្ធទាំងពីរលាយឡំគ្នានៅកម្ពុជា និងស្វែងរកចម្លើយថា តើ D&D ជួយពង្រឹងរបបប្រជាធិបតេយ្យនៅកម្ពុជា

ដែរឬទេ ។ ទិន្នន័យស្ទើរតែទាំងអស់ បានប្រមូលរួចរាល់ ហើយអត្ថបទព្រាងដំបូង រំពឹងថានឹងចប់ស្រេចបាច់នៅចុងខែមីនា ។ គម្រោង "អង្កេតមូលដ្ឋានអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ" សំដៅពិនិត្យពីចំណាប់អារម្មណ៍ និងការយល់ឃើញរបស់សមាជិកក្រុមប្រឹក្សាឃុំ ចំពោះរដ្ឋបាលថ្នាក់ស្រុក និងខេត្ត (ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក និងខេត្ត) ។ ការប្រមូលទិន្នន័យគ្រោងចប់សព្វគ្រប់នៅសប្ដាហ៍ទី២ ក្នុងខែកុម្ភៈ ។ គម្រោង "កំណែទម្រង់វិស័យសាធារណៈ ដើម្បីកសាងអភិបាលកិច្ចល្អលើទឹកស្រោចស្រពនៅកម្ពុជា" សំដៅវិភាគលើគម្លាតរវាងគោលនយោបាយកំណែទម្រង់វិស័យសាធារណៈ និងលទ្ធផលជាក់ស្ដែង ដោយផ្អែកលើការយល់ឃើញរបស់សហគមន៍កសិករប្រើប្រាស់ទឹក ។ គម្រោង "អភិបាលកិច្ចដែនរងទឹកភ្លៀង និងបញ្ហាចោទ ក្នុងកិច្ចសហប្រត្តិបត្តិការ" ពិនិត្យស្រាវជ្រាវពីកិច្ចសហប្រត្តិបត្តិការរវាងភាគីពាក់ព័ន្ធនានាក្នុងបរិបទកំណែទម្រង់ D&D ។ ការសិក្សានេះមានដំណើរការល្អ ហើយបច្ចុប្បន្នក្រុមស្រាវជ្រាវកំពុងប្រមូលទិន្នន័យ ។ ការស្រាវជ្រាវស្ដីពី "ការអនុវត្តអភិបាលកិច្ចធារាសាស្ត្រនៅកម្ពុជា" សំដៅអង្កេតលើកម្រិតស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច និងការងារចាំបាច់ដែលផុសចេញលក្ខណៈជាក់ស្ដែងនៃប្រព័ន្ធធារាសាស្ត្រ ។ ក្រុមស្រាវជ្រាវចងក្រងឯកសារអង្កេតនេះ បានជាង ៧០% ហើយគ្រោងចុះសិក្សាដល់កន្លែងពីរ-បីលើកទៀត ដើម្បីប្រមូលទិន្នន័យចាំបាច់ៗ ។

### កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវធំៗ ចំនួន ៤ ។ មកទល់បច្ចុប្បន្ន លទ្ធផលសំខាន់ៗនៃ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក ដែលចែកចេញជាសមាសភាគអភិបាលកិច្ច សមាសភាគរូបវន្ត និងសមាសភាគសេដ្ឋកិច្ច រួមមាន៖ អត្ថបទបោះពុម្ពផ្សាយចំនួន ៩ វគ្គសិក្សាចំនួន ៥ នៅក្នុងកម្មវិធីសិក្សារបស់ដេប៉ាតេម៉ង់វិទ្យាសាស្ត្របរិស្ថាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ អ្នកស្រាវជ្រាវ ២នាក់ បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត អ្នកស្រាវជ្រាវ ១នាក់ កំពុងបន្តការសិក្សាថ្នាក់បណ្ឌិត ការកសាងសមត្ថភាពភ្ជាប់នឹងការងារ (រួមមានការចុះស្រាវជ្រាវដល់កន្លែងច្រើនលើក ទស្សនកិច្ចសិក្សា ១លើក ការស្រាវជ្រាវសកម្ម និងការរៀនសូត្រ ដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធក្នុងតំបន់ និងថ្នាក់ក្រោមជាតិជាច្រើន) កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់ ៧លើក សិក្ខាសាលាថ្នាក់ខេត្ត ១២លើក និងសិក្ខាសាលាថ្នាក់ជាតិ ២លើក ។ គម្រោង "ព្រៃតំបន់ត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ–ការវិភាគទិន្នន័យតាំងពីកម្រិតគ្រួសារដល់កម្រិតសាកល" បានធ្វើឡើងដើម្បីពង្រីកចំណេះដឹងអំពីតួនាទីនៃព្រៃតំបន់ត្រូពិច ក្នុងការកាត់បន្ថយភាពក្រីក្រ ។ ឯកសារពិភាក្សាបានតាក់តែងរួចរាល់ ហើយលទ្ធផលស្រាវជ្រាវ ក៏បានលើកបង្ហាញជូនដល់ប្រជាជនក្នុងភូមិស្រាវជ្រាវនៅខេត្តកំពង់ធំ កំពង់ស្ពឺ និងកំពត ។ គម្រោង "ការកសាងសមត្ថភាពសហគមន៍ សម្រាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប (JFPR-9114-CAM)" គឺសំដៅជួយទ្រទ្រង់ដល់ការអភិវឌ្ឍសមត្ថភាព ក្នុងការរៀបចំសហគមន៍និងភូមិ និងកសាងសមត្ថភាពសហគមន៍ ដើម្បីពន្លឿនការកាត់បន្ថយភាពក្រីក្រ ។ លទ្ធផលគម្រោងនេះមានជាអាទិ៍ (១) មជ្ឈមណ្ឌលធនធានទន្លេសាបដែលមានទាំងបណ្ណាល័យតាមប្រព័ន្ធអ៊ិនធឺណិត និងកាតាឡុក (២) អង្កេតស្ដីពីសមត្ថភាព និងការត្រៀមខ្លួនរបស់ក្រុមប្រឹក្សាឃុំ ក្នុង ៩៧ឃុំ ព្រមទាំងរបាយការណ៍ព្រាងដែលបានសរសេររួចរាល់ និង (៣) សិក្ខាសាលាថ្នាក់ខេត្តចំនួន៥ ដែលមានទាំងការវិភាគ និងរបាយការណ៍សិក្ខាសាលា ។

គម្រោង "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងអង្កេតមូលដ្ឋានវាយតម្លៃភាពងាយរងគ្រោះ" កំពុងដំណើរការ ដើម្បីស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងកម្រិតពឹងផ្អែករបស់ប្រជាជននៅតាមដងទន្លេមេគង្គទៅលើធនធានទឹក ។

### កម្មវិធីតាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ

កម្មវិធីនេះកំពុងអនុវត្តគម្រោងស្រាវជ្រាវចំនួន ៤ ។ ការចុះសិក្សាវាយតម្លៃសាកល្បងដល់កន្លែងសម្រាប់ គម្រោង "ការវាយតម្លៃពី ផលប៉ះពាល់នៃអង្គការកសិករលើសន្តិសុខស្បៀងសម្រាប់ជនក្រីក្រនៅជនបទ" បានចប់សព្វគ្រប់ ហើយបញ្ជីសំណួរអង្កេត និងសំណួរណែនាំបែបគុណភាព បានរៀបចំរួចហើយសម្រាប់ ដាក់បញ្ចូលក្នុងរបាយការណ៍បណ្ដោះអាសន្ន ស្ដីពីលទ្ធផលរកឃើញដំបូងៗ បានពីការវាយតម្លៃសាកល្បង ។ ចំពោះគម្រោង "ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់ សម្រាប់សកម្មភាពដោះមីននៅកម្ពុជា" ក្រុមស្រាវជ្រាវ បានបញ្ចប់ការពិនិត្យឡើងវិញលើឯកសារមានស្រាប់ និងទិន្នន័យថ្នាក់ជាតិ ដើម្បីកំណត់ពីចំណុចនៅខ្វះចន្លោះ និងសូចនាករពាក់ព័ន្ធនានា ។ របាយការណ៍ព្រាងដំបូង បានប្រគល់ជូន UNDP និងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន (CMAA) រួចហើយ ដើម្បីសុំយោបល់បន្ថែម ។ របាយការណ៍អំពីករណីសិក្សាស៊ីជម្រៅចំនួន ៤ បានចប់ស្រេចបាច់ ហើយរបាយការណ៍សំយោគមួយ កំពុងចងក្រងឡើងសម្រាប់គម្រោងស្ដីពី "ភាពរលូនគ្នាខាងគោលនយោបាយ សម្រាប់ការអភិវឌ្ឍជនបទ និងកសិកម្ម ។ ចំពោះរបាយការណ៍ស្ដីពី "ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ (PDS)" ដែលជាគម្រោងរួមគ្នាជាមួយកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រត្តិបត្តិការក្នុងតំបន់នៃ CDRI ដែរ ក្រុមស្រាវជ្រាវកំពុងកែសម្រួលសម្រេច ដោយផ្អែកលើមតិយោបល់របស់ធនាគារពិភពលោក ។

### កម្មវិធីអភិវឌ្ឍសង្គម

គម្រោងស្រាវជ្រាវទី១ គឺ ការបោះពុម្ពផ្សាយជាលក្ខណៈ អន្តរជាតិនូវសៀវភៅមានចំណងជើងថា "ការលើកកម្ពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទះចិត្ត និងការលើកទឹកចិត្ត" ដែលទទួលបានមូលនិធិពីសាកលវិទ្យាល័យស្រាវជ្រាវ (University of Research Co., LLC) ។ បច្ចុប្បន្ន ឯកសារសម្រេចកំពុងរៀបចំដោយ វិទ្យាស្ថានសិក្សាពីអាស៊ីអាគ្នេយ៍ (ISEAS) ។

ការបោះពុម្ពសៀវភៅនេះ ជាកិច្ចប្រឹងប្រែងចងក្រង និងផ្សព្វផ្សាយនូវបទពិសោធន៍ក្នុងតំបន់ និងអន្តរជាតិ របស់អ្នកជំនាញខាងសុខាភិបាល លើបញ្ហា ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្តក្នុងវិស័យសុខាភិបាល ។ គម្រោងស្រាវជ្រាវទី២ គឺ គំនិតផ្តួចផ្តើម EQUITAP[១] ដែលទទួលបានហិរញ្ញប្បទានពីទីភ្នាក់ងារអូស្ត្រាលី សម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) និងសម្របសម្រួលដោយ វិទ្យាស្ថានសម្រាប់គោលនយោបាយសុខាភិបាលនៃប្រទេសស្រីលង្កា ។ គម្រោងនេះ សំដៅវិភាគលើទិន្នន័យអង្កេតគ្រួសារមានស្រាប់ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រនិងជួបមហន្តរាយ ការវិវត្តទៅមុខ ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងអត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល ។ ក្រុមស្រាវជ្រាវបានប្រគល់លទ្ធផលដំបូងៗនៃការវិភាគ ទៅឲ្យអ្នកសម្របសម្រួលគម្រោង ដើម្បីសុំមតិបន្ថែម និងបានសរសេរអត្ថបទមួយស្តីពី "ការវាយតម្លៃពីចំណាយមហន្តរាយ លើការថែទាំសុខភាពគ្រួសារ" សម្រាប់ចុះផ្សាយក្នុងសង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ របស់ CDRI ។ ក្នុងពេលដ៏ខ្លីខាងមុខ កម្មវិធីនេះនឹងចាប់ដំណើរការគម្រោងស្រាវជ្រាវរយៈពេល ៦ឆ្នាំ មួយ ស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលសម្រាប់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញ ក្រោយបញ្ចប់ទំនាស់" ឬហៅកាត់ថា "REBUILD (ការកសាងជាថ្មី)" ដែលទទួលបានហិរញ្ញប្បទាន ពីក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID-UK) ។ ក្រោមការដឹកនាំពី Liverpool School of Tropical Medicine នៃចក្រភពអង់គ្លេស គម្រោងនេះស្វែងរកជាភស្តុតាងល្អៗ ដើម្បីជួយរួមចំណែកលើកកម្ពស់សុខភាពប្រជាជនក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ វិទ្យាស្ថានជាដៃគូផ្សេងទៀតក្នុងបណ្តាញស្រាវជ្រាវនេះ រួមមាន (១) សាកលវិទ្យាល័យ Makerere នៃប្រទេស Uganda (២) College of Medicine and Allied Health Sciences នៃប្រទេស Sierra Leone (៣) Biomedical Research and Training Institute នៃប្រទេស Zimbabwe និង (៤) Institute for International Health and Development នៃទីក្រុង Edinburgh ចក្រភពអង់គ្លេស ។

ក្រុមស្រាវជ្រាវក្នុងកម្មវិធីបណ្តុះបណ្តាល និងកសាងសន្តិភាព កំពុងបន្តការងារលើសិក្ខាសាលាចំនួន៣ គឺ ការបណ្តុះបណ្តាលផ្អែកលើករណីសិក្សា ស្តីពីទំនាស់លើការប្រើប្រាស់ទឹកក្នុងខេត្តកំពង់ឆ្នាំង ការបណ្តុះបណ្តាលជាក់លាក់មួយនៅខេត្តពោធិ៍សាត់ និងវគ្គបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញ ស្តីពីតួនាទីនៃប្រព័ន្ធផ្សព្វផ្សាយក្នុងការកសាងសន្តិភាព ។ ក្រុមស្រាវជ្រាវ ក៏កំពុងធ្វើការបណ្តុះបណ្តាលផ្អែកលើករណីសិក្សាមួយទៀត ស្តីពីទំនាស់លើការប្រើប្រាស់ទឹកនៅខេត្តកំពង់ធំ ។

១ EQUITAP ឬ Equity in Asia-Pacific Health System (សមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក) ជាកិច្ចប្រឹងប្រែងរួមគ្នារបស់អ្នកស្រាវជ្រាវជាង ១៥ក្រុម នៅអាស៊ី និងអឺរ៉ុប ដើម្បីពិនិត្យពីសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានានៅអាស៊ីប៉ាស៊ីហ្វិក ។ កិច្ចសហការណ៍នេះ រួមមានការកសាងឧបករណ៍សម្រាប់ស្រាវជ្រាវ និងការវាយតម្លៃជាក់ស្តែងលើការអនុវត្តនៃប្រព័ន្ធសុខាភិបាលជាតិនានា ។




ជាភាសាខ្មែរ
**ថ្លៃ ១០.០០០៛**

ជាភាសាអង់គ្លេស
**ថ្លៃ ១២.០០០៛**

## ទើបចេញផ្សាយថ្មីៗ
ឯកសារពិភាក្សាលេខ ៤៩

### ការប្រើប្រាស់ចំណេះដឹងធារាសាស្ត្រ និងការចូលរួមពីសហគមន៍ ដើម្បីឲ្យមានការសម្រេចចិត្តកាន់តែប្រសើរ ក្នុងការបែងចែកទឹកស្រោចស្រព

ដោយលោក ចែម ផល្លា និងលោក សុម៉េធ ប៉ារ៉ាឌី

កំណើនប្រជាជន បានធ្វើឲ្យតំរូវការស្បៀងអាហារកើនឡើង ។ ដើម្បីដោះស្រាយតំរូវការនេះ មនុស្សរុករកអាហារពីធនធានធម្មជាតិ និងធ្វើកសិកម្មផលិតអាហារឲ្យបានច្រើនជាអតិបរមា ។ ប៉ុន្តែកសិករភាគច្រើនដែលធ្វើស្រែតាមរដូវកាល ខ្វះលទ្ធភាពស្រោចស្រព ។

កង្វះនេះ មិនមែនដោយសារគ្មានទឹកទេ តែវាជាកង្វះហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងយន្តការបែងចែកទឹកសមស្រប ។

ឯកសារនេះរាយការណ៍ពី ការសិក្សាស្រាវជ្រាវលើផ្ទៃរងទឹកភ្លៀងក្នុងខេត្តកំពង់ឆ្នាំង សំដៅពង្រីកចំណេះដឹងពីទំនាក់ទំនងការប្រើប្រាស់ទឹក គោលនយោបាយ ប្រព័ន្ធរូបវ័ន្ត និងក្របខ័ណ្ឌស្ថាប័ន ជុំវិញការគ្រប់គ្រងទឹក ។ ការសិក្សាស្រាវជ្រាវនេះប្រើវិធីសាស្ត្រស្រាវជ្រាវសកម្មភាពដោយមានការចូលរួម ដើម្បីសិក្សាពីអន្តរកម្ម និងការប្រមូលទិន្នន័យ ។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

CDRI ទទួលបានលទ្ធផលហិរញ្ញវត្ថុល្អនៅឆ្នាំ២០១០ និងបានពង្រីកធនធានមូលដ្ឋានរបស់ខ្លួនថែមទៀត ទាំងហិរញ្ញវត្ថុ និងធនធានមនុស្ស ដោយមាននៅសល់ចំណូលខ្លះសម្រាប់ដាក់បញ្ចូលក្នុងទុនបម្រុង ។ ទោះយ៉ាងនេះក្ដី បញ្ហាចីរភាពក្នុងរយៈពេលវែងនៅតែមានចោទ ហើយ CDRI ព្យាយាមស្វែងរកដៃគូផ្ដល់ធនធានរយៈពេលវែង ក្នុងចំណោមស្ថាប័នអភិវឌ្ឍន៍អន្តរជាតិនានា និងតុល្យភាពកាន់តែប្រសើររវាងការផ្ដល់ធនធានតាមរយៈកម្មវិធី និងការផ្ដល់ធនធានតាមរយៈគម្រោង នៅក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ របស់ខ្លួន ។ របាយការណ៍ប្រចាំឆ្នាំ២០១០-១១ របស់ CDRI អាចរកមើលបានក្នុងគេហទំព័ររបស់ CDRI។

នៅថ្ងៃទី២៤-២៥ មករា នាយកប្រតិបត្តិនៃ CDRI បានចូលរួមក្នុងសិក្ខាសាលាបំផុសគំនិត នៃវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី/ការសិក្សារបស់ធនាគារអភិវឌ្ឍអាស៊ី ស្ដីពីតួនាទីនៃសេដ្ឋកិច្ចកំពុងស្ទុះឡើងសំខាន់ៗ គឺមាន អាស៊ាន ចិន និងឥណ្ឌា(ACI) ដើម្បីឲ្យតំបន់អាស៊ី និងអាស៊ាន មានតុល្យភាព ចីរភាព និងភាពរឹងមាំ នៅឆ្នាំ២០៣០៖ ការរីកលូតលាស់ទាំងអស់គ្នាដើម្បីភាពរុងរឿងរួមគ្នា នៅឯវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី នៅទីក្រុងតូក្យូ ។ CDRI បានទទួលកិច្ចសន្យាឲ្យរៀបចំឯកសារព័ត៌មានទូទៅពីប្រទេសកម្ពុជា សម្រាប់ការសិក្សាអំពីអាស៊ានឆ្នាំ២០៣០ ។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៥ ស្ដីពី "ជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍ ប្រកបដោយចីរភាពនៅប្រទេសកម្ពុជា៖ កាលានុវត្តភាព និងបញ្ហាប្រឈម" ដែលជាកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារ ANZ Royal បានប្រារព្ធឡើងនៅទីក្រុងភ្នំពេញ នៅថ្ងៃទី១៦ មីនា ២០១១ ។ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទទៅកាន់អ្នកចូលរួមជាង ៣០០នាក់ ។ សន្និសីទនៅឆ្នាំ២០១១ នេះ ចែកចេញជាវគ្គជាច្រើន មានជាអាទិ៍ ១) សូចនាករ ការរំពឹងទុក និងអាទិភាពខាងគោលនយោបាយ ២) បរិយាកាសជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា - កត្តាសំខាន់ៗ ៣) អាទិភាពផ្នែកគោលនយោបាយ និងសកម្មភាព ។

នៅថ្ងៃទី ១៧ មីនា ក្រុមប្រឹក្សាភិបាលនៃ CDRI បានអនុម័តលើឯកសារថ្មីរបស់ CDRI ស្ដីពីយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ ។ យុទ្ធសាស្ត្រស្រាវជ្រាវ មានប្រធានបទពាក់ព័ន្ធគោលនយោបាយអាទិភាពចំនួន៥ ដែលឆ្លុះបញ្ចាំងពីកម្មវិធីទាំង៥របស់ CDRI គឺមាន ១) សេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ ២) កសិកម្ម និងអភិវឌ្ឍន៍ជនបទ ៣) អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ៤) ធនធានធម្មជាតិ និងបរិស្ថាន ៥) អភិវឌ្ឍន៍សង្គម ព្រមទាំងប្រធានបទចម្រុះ៤ទៀត ពាក់ព័ន្ធនឹងច្រើនកម្មវិធី គឺមាន ចីរភាព

*(តទៅទំព័រ ២៥)*

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១៥ លេខ១ ខែមករា-មីនា ឆ្នាំ២០១១

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្ដល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួល: ខេង សេង និង អ៊ឹង សុជាតិ
រោងពុម្ពអង្គរអុហ្វសិត ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១១ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ឱ្យដោយឥតគិតថ្លៃតាមរយៈគេហទំព័រ: http://www.cdri.org.kh